ក្រសួងមុខងារសាធារណៈ

លេខ០១ ខែកញ្ញា ឆ្នាំ២០២៣ - ខែកុម្ភៈ ឆ្នាំ២០២៤

ព្រឹត្តិបត្រព័ត៌មាន
កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ

«កែទម្រង់ណាក៏ដោយ ត្រូវចាប់ផ្តើមពីខ្លួនឯងជាមុនសិន»
ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

អគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

មាតិកា

ព្រឹត្តិបត្រព័ត៌មានកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ
ខែកញ្ញា ឆ្នាំ២០២៣ - ខែកុម្ភៈ ឆ្នាំ២០២៤

ព្រឹត្តិការណ៍

ទំព័រទី១
ការរៀបចំយន្តការ ស្ថាប័នក្នុងក្របខណ្ឌ ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ទំព័រទី១
ការផ្សព្វផ្សាយផែនការ និងការអនុវត្តការងារស្របតាមទស្សនវិស័យ និងការណែនាំរបស់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី លើក្របខណ្ឌមន្ត្រីរាជការស៊ីវិល

ទំព័រទី២
ការពិភាក្សាលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការងារកែទម្រង់ក្នុងក្របខណ្ឌការដ្ឋានកែទម្រង់៣បូក១ សម្រាប់ឆ្នាំ ២០២៣ និងត្រៀមអនុវត្តផែនការសម្រាប់ឆ្នាំ២០២៤

ទំព័រទី៣
ការគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ សម្រាប់ការអនុវត្តការងារកែទម្រង់របស់រាជរដ្ឋាភិបាល

ទំព័រទី៤
ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា

ទំព័រទី៥
ការរៀបចំក្រុមការងារនីតិវិធី និងបែបបទស្តីពីការជ្រើសរើសក្របខណ្ឌគ្រូបង្រៀនឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣

ទំព័រទី៥
ការរៀបចំនីតិវិធីប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិលរបស់អង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់ឆ្នាំ២០២៣

ទំព័រទី៦
គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ(គ.វ.ជ)ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលសម្រាប់ឆ្នាំ២០២២-២០២៣

ទំព័រទី៧
ការពិភាក្សាការងារកម្រិតថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ទំព័រទី៨
ការពិភាក្សាការងាររបស់ក្រុមការងារបច្ចេកទេសទាំង៣ក្រុម នៃ គ.វ.រ និងអនុគណៈកម្មាធិការទាំង៤ នៃ គ.ក.ស.

ទំព័រទី៩
ការចុះអនុវត្តលើការវាយតម្លៃជាក់ស្តែងដល់ទីតាំងបេក្ខភាពសាលាបឋមសិក្សា របស់គណៈកម្មការបច្ចេកទេសអន្តរក្រសួង និងក្រុមការងារលេខាធិការដ្ឋាននៃ គ.វ.ជ.

ទំព័រទី១០
កាលបរិច្ឆេទសម្រាប់ការចុះវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនៅទីតាំងជាក់ស្តែងរបស់ គ.វ.ជ

ទំព័រទី១១
កាលបរិច្ឆេទសម្រាប់ការចុះវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាលនៅទីតាំងជាក់ស្តែងរបស់ គ.វ.ជ

ទំព័រទី១២
ពិធីសំណេះសំណាលលើកដំបូង ជាមួយសមាជិកសមាជិកា របស់ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.ស)

ទំព័រទី១៣
ក្រសួងមុខងារសាធារណៈ ប្រជុំពិភាក្សាការងារជាមួយ តំណាងធនាគារពិភពលោកប្រចាំនៅកម្ពុជា

ទំព័រទី១៤
ការបន្តពិនិត្យ និងពិភាក្សារៀបចំផែនការសកម្មភាព ឆ្នាំ២០២៤ របស់អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ទំព័រទី១៥
វឌ្ឍនភាពការងារក្រុមការងារបច្ចេកទេសទាំង៣ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ គ.វ.រ.

ទំព័រទី១៦
កិច្ចប្រជុំរៀបចំផែនការសកម្មភាពឆ្នាំ២០២៤ សម្រាប់ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល

ទំព័រទី១៧
ពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការ កែទម្រង់រដ្ឋបាលសាធារណៈ

ទំព័រទី១៩
កិច្ចពិភាក្សា ក្រុមការងារបច្ចេកទេស ពិនិត្យការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងមុខងារសាធារណៈ ដើម្បីជំរុញដល់ការអនុវត្តគោលនយោបាយគន្លឹះរបស់រាជរដ្ឋាភិបាល

ទំព័រទី២១
ការវាយតម្លៃ និងពិនិត្យឡើងវិញលើដំណើរការនៃការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣ ចំនួន ២៥០កន្លែងឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ទំព័រទី២៣
ការពិនិត្យ ពិភាក្សាលើការផ្ទេរមុខងារលើវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ទំព័រទី២៤
ការពិនិត្យ សេចក្តីព្រាងផែនការសកម្មភាព ជាយុទ្ធសាស្ត្ររបស់ក្រុមការងារបច្ចេកទេសទាំង៣ក្រុម នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ.

ទំព័រទី២៥
ការដឹកនាំគណៈកម្មការបច្ចេកទេសអន្តរក្រសួង និងក្រុមការងារលេខាធិការដ្ឋាន នៃ គ.វ.ជ ចុះអនុវត្តការវាយតម្លៃនៅទីតាំងជាក់ស្តែង

ទំព័រទី២៧
ការពិនិត្យ និងតម្រង់ទិសការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់ក្រសួងមុខងារសាធារណៈ

ទំព័រទី២៩
ការប្រជុំពិភាក្សាការងារផ្ទៃក្នុងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ទំព័រទី៣០
ការពិនិត្យវឌ្ឍនភាពការងារប្រឡងប្រជែងជ្រើសរើសក្របខណ្ឌគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣និងការត្រៀមរៀបចំការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌរបស់ក្រសួង ស្ថាប័នដទៃទៀត

ទំព័រទី៣១
ការពិនិត្យវឌ្ឍនភាពការងារ និងពិភាក្សាផែនការសកម្មភាពឆ្នាំ២០២៤ ព្រមទាំងបែងចែក តួនាទីភារកិច្ច របស់ក្រុមការងារអនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍

ទំព័រទី៣២
ការពិភាក្សាលើការងារប្រឡងប្រជែងជ្រើសរើសក្របខណ្ឌគ្របង្រៀនឯកទេសអប់រំកាយ និងកីឡាឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣

ទំព័រទី៣៣
ការពិភាក្សា និងពិនិត្យលើផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ.

ទំព័រទី៣៤
ការពិនិត្យ និងពិភាក្សាលើឯកសារនិយាមនីតិវិធីប្រតិបត្តិស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ និងឯកសារទស្សនទានស្តីពីការជ្រើសរើសនិងការប្រើប្រាស់មន្ត្រីបច្ចេកទេសសុខាភិបាល

ទំព័រទី៣៥
ការពិនិត្យ និងពិភាក្សាលើឯកសារនិយាមនីតិវិធីប្រតិបត្តិ ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល

ទំព័រទី៣៦
ការពិនិត្យ ពិភាក្សាការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការពិនិត្យស្ថានភាពបុគ្គលិកសុខាភិបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ទំព័រទី៣៧
ការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងក្របខណ្ឌអគ្គលេខាធិការដ្ឋាន គ.ក.ស.

ទំព័រទី៣៨
ការពិនិត្យសកម្មភាពតាក់តែងវិញ្ញាសារបស់គណៈមេប្រយោគនៃគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើស គ្រូបង្រៀនឯកទេសអប់រំ កាយ និងកីឡា

ទំព័រទី៣៩
នីតិវិធីនៃការពិនិត្យលើលទ្ធផលនៃការវាយតម្លៃនៅទីតាំងជាក់ស្តែង បេក្ខភាពសម្រាំង អនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខភាពគំរូ របស់គណៈកម្មការបច្ចេកទេសអន្តរក្រសួង នៃ គ.វ.ជ.

ទំព័រទី៤០
ការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍នៃការបង្កើតអង្គភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង-ស្ថាប័ន

ទំព័រទី៤១
ការពិនិត្យ និងពិភាក្សាការងាររបស់ក្រុមការងារកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មនៃអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ.

ទំព័រទី៤២
ការពិនិត្យ និងពិភាក្សាលើឯកសារទស្សនទានស្តីពីការជ្រើសរើស និងការប្រើប្រាស់មន្ត្រីបច្ចេកទេសសុខាភិបាល

ទំព័រទី៤៣
ការពិនិត្យ និងពិភាក្សាលើផែនការសកម្មភាពរបស់អនុគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈទាំង៤ នៃ គ.ក.ស. សម្រាប់អនុវត្តក្នុងឆ្នាំ២០២៤

ទំព័រទី៤៤
កិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យ និងពិភាក្សារកធាតុចូល អំពីសេចក្តីព្រាងនិយាមនីតិវិធីប្រតិបត្តិ(SOP)សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល

ទំព័រទី៤៥
ដំណាក់កាលពិនិត្យវាយតម្លៃចុងក្រោយ របស់គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ(គ.វ.ជ)ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលឆ្នាំ២០២៣

ទំព័រទី៤៦
ជំនួបពិភាក្សារបស់ក្រសួងមុខងារសាធារណៈជាមួយក្រុមការងារធនាគារពិភពលោកប្រចាំនៅកម្ពុជា ជុំវិញការងារបណ្ដុះបណ្ដាលធនធានមនុស្ស

ទំព័រទី៤៧
ក្រសួងមុខងារសាធារណៈ ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សារៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ៥ ក្រសួងស្ថាប័នទៀត

ទំព័រទី៤៨
ក្រសួងមុខងារសាធារណៈ ជួបជាមួយក្រុមការងារអន្តរក្រសួង ដើម្បីពិភាក្សាលើបច្ចុប្បន្នកម្មនៃប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ទំព័រទី៤៩
ប្រតិភូក្រសួងមុខងារសាធារណៈ ចូលរួមកិច្ចប្រជុំក្របខណ្ឌការដ្ឋានកែទម្រង់ ៣ បូក ១

ទំព័រទី៥០
ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហ៊ុន ម៉ានី** ៖ ការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូជាផ្នែកមួយបង្ហាញពីឧត្តមភាពនៃមន្ត្រីរាជការស៊ីវិលគ្រប់ជាន់ថ្នាក់

ទំព័រទី៥១
សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីប្រកាសជ័យលាភី អង្គភាពផ្ដល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងសុខាភិបាល ឆ្នាំ២០២៣ និងប្រកាសដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ២០២៤

ទំព័រទី៥២
គណៈកម្មការរៀបចំការប្រឡងប្រជែង ប្រជុំពិនិត្យពិភាក្សាលើការរៀបចំដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ចំនួន ៣ ក្រសួង-ស្ថាប័ន

ទំព័រទី៥៣
ក្រសួងមុខងារសាធារណៈ រៀបចំកិច្ចប្រជុំអន្តរក្រសួង ពិនិត្យ និងពិភាក្សា លើការរៀបចំដំឡើងប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភ សម្រាប់មន្ត្រីរាជការក្នុងឆ្នាំ២០២៤

ទំព័រទី៥៥
ការពិភាក្សា អំពីផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ

ទំព័រទី៥៦
ការពិនិត្យនិងពិភាក្សាលើផែនការសកម្មភាពឆ្នាំ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈសម្រាប់ក្រសួងស្ថាប័ន និងថ្នាក់ក្រោមជាតិ

សន្និសីទសារព័ត៌មាន

ទំព័រទី៥៧
សន្និសីទអន្តរជាតិ ស្ដីពីអនាគតវិស័យមុខងារសាធារណៈ

ទំព័រទី៥៨
ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលជាលើកដំបូងសម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៧ដែលដឹកនាំអនុវត្តដោយក្រសួងមុខងារសាធារណៈ

ទំព័រទី៥៩
សន្និសីទសារព័ត៌មានស្ដីពី "ការរៀបចំការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា"

សិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាល

ទំព័រទី៦០
សិក្ខាសាលាស្ដីពី ការកសាងសមត្ថភាពលើភាពជាអ្នកដឹកនាំប្រកបដោយបរិវត្តកម្ម សម្រាប់មន្ត្រីជាន់ខ្ពស់ នៃប្រទេសជាសមាជិកអាស៊ាន និងប្រទេសទីម័រខាងកើត

ទំព័រទី៦១
ពិធីបិទវគ្គបណ្ដុះបណ្ដាលនៃភាពជាអ្នកដឹកនាំ និងនវានុវត្តន៍

ទំព័រទី៦២
សិក្ខាសាលាចែករំលែកបទពិសោធនៃការគ្រប់គ្រង និងការផ្ដល់សេវាសាធារណៈ របស់ជ័យលាភីអង្គភាពផ្ដល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឆ្នាំ២០២៣

លិខិតបទដ្ឋានគតិយុត្ត

ទំព័រទី៦៣
ព្រះរាជក្រឹត្យ នស/រកត/០៩២៣/២១៤៣/ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា

ទំព័រទី៦៣
ព្រះរាជក្រឹត្យ នស/រកត/០៩២៣/២១៤១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រដ្ឋាភិបាល

ទំព័រទី៦៤
ព្រះរាជក្រឹត្យ នស/រកត/០៩២៣/២១៤២ ស្ដីពីការរៀបចំការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាលរបស់រាជរដ្ឋាភិបាល

ទំព័រទី៦៤
ព្រះរាជក្រឹត្យ នស/រកត/១០២៣/២៣១២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ទំព័រទី៦៥
អនុក្រឹត្យ៣២៥ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ទំព័រទី៦៦
អនុក្រឹត្យស្ដីពីការដំឡើងរបបឧបត្ថម្ភប្រចាំខែសម្រាប់អ្នកនៅក្នុងបន្ទុករបស់សពមន្ត្រីរាជការស៊ីវិលសពអតីតមន្ត្រីរាជការស៊ីវិល និងសពអតីតយុទ្ធជន

ទំព័រទី៦៦
សេចក្ដីជូនដំណឹង លេខ ១២០៥ ស.ជ.ណ ស្ដីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល

ទំព័រទី៦៨
អនុក្រឹត្យ ស្ដីពីការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា

ទំព័រទី៦៨
អនុក្រឹត្យ ស្ដីពីការទទួលស្គាល់ជ័យលាភីអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល

ទំព័រទី៦៩
អនុក្រឹត្យ ស្ដីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ

ទំព័រទី៦៩
អនុក្រឹត្យ ស្តីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល

ទំព័រទី៧០
ប្រកាសអន្តរក្រសួងស្តីពីការដាក់ឱ្យដំណើរការវាយតម្លៃ និងការទទួលស្គាល់ អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២៤

ទំព័រទី៧០
ប្រកាសអន្តរក្រសួងស្តីពីការដាក់ឱ្យដំណើរការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យ អប់រំ សម្រាប់ឆ្នាំ២០២៤

ប្រសាសន៍ណែនាំ

ទំព័រទី៧១
ប្រសាសន៍ណែនាំ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទំព័រទី៧២
ប្រសាសន៍ណែនាំសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទំព័រទី៧៣
ប្រសាសន៍ណែនាំឯកឧត្តម **ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

ផ្នែកទី១៖ ព្រឹត្តិការណ៍

ការរៀបចំយន្តការស្ថាប័នក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

(កាលបរិច្ឆេទ៖ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ កិច្ចប្រជុំជាមួយថ្នាក់ដឹកនាំក្រសួងដើម្បីពង្រឹងយន្តការស្ថាប័ន និងសម្រេចកិច្ចការងារកំណែទម្រង់)

នាពេលរសៀលថ្ងៃសុក្រ ទី០១ ខែកញ្ញា ឆ្នាំ២០២៣ **ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** បានដឹកនាំកិច្ចប្រជុំបច្ចេកទេសកម្រិតថ្នាក់ដឹកនាំផ្ទៃក្នុងក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើការរៀបចំយន្តការស្ថាប័នក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ នៅទីស្តីការរបស់ក្រសួងមុខងារសាធារណៈ។ មុនឈានដល់ការពិភាក្សា **ឯកឧត្តមរដ្ឋមន្ត្រី** បានគូសបញ្ជាក់ និងរំលឹកជូនដល់អង្គប្រជុំនូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃ **ព្រះរាជាណាចក្រកម្ពុជា** លើមូលដ្ឋានគ្រឹះចម្បងនៃការគិតគូររៀបចំតែងតាំងមន្ត្រី និងការគ្រប់គ្រងបែងចែកតួនាទីប្រគល់ភារកិច្ចដល់មន្ត្រីតាមក្រសួងស្ថាប័នរដ្ឋ។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅដោយរលូនជាមួយការចូលរួមយោបល់ជាធាតុចូលយ៉ាងផុសផុលពីសំណាក់អង្គប្រជុំ ក្នុងការពិនិត្យ ពិភាក្សាលើឯកសារសេចក្តីព្រាងព្រះរាជក្រឹត្យ និងអនុក្រឹត្យគោលសំខាន់ៗដែលមានក្នុងរបៀបវារៈកិច្ចប្រជុំ។ **ឯកឧត្តមរដ្ឋមន្ត្រី**ក៏បានចែករំលែកជូនថ្នាក់ដឹកនាំនូវកត្តាដែលចាំបាច់ក្នុងការងារកែទម្រង់ រួមមាន៖ **ឆន្ទៈនយោបាយ តួអង្គដឹកនាំអនុវត្ត និងការចូលរួមទាំងអស់គ្នា។**

ការផ្សព្វផ្សាយផែនការ និងការអនុវត្តការងារស្របតាមទស្សនវិស័យ និងការណែនាំរបស់សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី លើក្របខណ្ឌ មន្ត្រីរាជការស៊ីវិល

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម រដ្ឋមន្ត្រី** បានដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយផែនការ និងការអនុវត្តការងារស្របតាមទស្សនវិស័យ និងការណែនាំរបស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** លើក្របខណ្ឌមន្ត្រីរាជការស៊ីវិល។

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅដោយរលូនជាមួយការចូលរួមផ្តល់យោបល់ជាធាតុចូលយ៉ាងផុសផុលពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងអង្គប្រជុំទាំងមូលនូវកិច្ចពិភាក្សាលើរបៀបវារៈ និងបញ្ហាដែលធ្លាប់ជួបប្រទះកន្លងមក។

ការពិភាក្សាលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការងារកែទម្រង់ក្នុង ក្របខណ្ឌការដ្ឋានកែទម្រង់៣បូក១ សម្រាប់ឆ្នាំ២០២៣ និងត្រៀមអនុវត្តផែនការសម្រាប់ឆ្នាំ២០២៤

(ប្រតិភូក្រសួងមុខងារសាធារណៈ ចូលរួមកិច្ចប្រជុំក្របខណ្ឌការដ្ឋានកែទម្រង់៣បូក១)

ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម ឈុន សុជាតិ** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ បានដឹកនាំក្រុមការងារបច្ចេកទេសតំណាងលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ចូលរួមកិច្ចប្រជុំក្នុងក្របខណ្ឌការដ្ឋានកែទម្រង់ ៣ បូក ១ នៅសាលប្រជុំក្រសួងមហាផ្ទៃ។កិច្ចប្រជុំនេះដឹកនាំដោយសហប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប និងអគ្គលេខាធិការដ្ឋាន អ.គ.ហ ពិភាក្សាទៅលើការងារបច្ចេកទេសដូចតទៅ៖ កែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ដើម្បីពិនិត្យលើវឌ្ឍនភាពនិងបញ្ហាប្រឈមនៃការអនុវត្តការងារកែទម្រង់តាមការដ្ឋាននីមួយៗសម្រាប់ឆ្នាំ២០២៣ និងត្រៀមរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៤។

ជាលទ្ធផលរួមនៃកិច្ចប្រជុំក្នុងក្របខណ្ឌការដ្ឋានកែទម្រង់ ៣ បូក ១ បានឯកភាពលើខ្លឹមសារសំខាន់ៗចំនួន៣រួមមាន៖

១).ការធ្វើបច្ចុប្បន្នកម្មនៃផែនការសកម្មភាពសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ សម្រាប់ឆ្នាំ២០២៤

២).ការរៀបចំវិបស្សនារួមគ្នានៃការដ្ឋានកែទម្រង់ ៣ បូក ១ និងការរៀបចំធ្វើទស្សនកិច្ចរួមគ្នានៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅត្រីមាសទី១ ឆ្នាំ២០២៤ និង

៣).ការគ្រោងរៀបចំការផ្សព្វផ្សាយឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ក្នុងក្របខណ្ឌក្រសួង ស្ថាប័នសាមី។

ការគ្រប់គ្រងរដ្ឋបាលសាធារណៈ នៅថ្នាក់ក្រោមជាតិ សម្រាប់ការអនុវត្តការងារកែទម្រង់របស់រាជរដ្ឋាភិបាល

(ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងស្តីពីការគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ និងការត្រៀមរៀបចំសកម្មភាពសម្រាប់ការអនុវត្តការងារកែទម្រង់របស់រាជរដ្ឋាភិបាល)

នៅព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣នេះ **ឯកឧត្តមរដ្ឋមន្ត្រី ហ៊ុន ម៉ានី** បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រសួងស្តីពីការគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ និងការត្រៀមរៀបចំសកម្មភាពនានាសម្រាប់ការអនុវត្តការងារកែទម្រង់របស់រាជរដ្ឋាភិបាលនៅសហសាលសិក្សានៃសាលាភូមិន្ទរដ្ឋបាល។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមមកពីសំណាក់ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង លោក លោកស្រី ជាប្រធានមន្ទីររាជធានីខេត្ត ព្រមទាំងមន្ត្រីជំនាញសរុបប្រមាណចំនួន១៤០នាក់។

គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន និងផ្សព្វផ្សាយពីការត្រៀមរៀបចំសកម្មភាពបន្តស្របតាមគោលការណ៍ និងអនុសាសន៍ណែនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ជាពិសេសលើវិធានអាទិភាពគន្លឹះក្នុងការពង្រឹងរដ្ឋបាលសាធារណៈ។ ថ្លែងប្រសាសន៍ក្នុងកិច្ចប្រជុំឯកឧត្តមរដ្ឋមន្ត្រីបានគូសបញ្ជាក់ជូនដល់ថ្នាក់ដឹកនាំមន្ទីរមុខងារសាធារណៈក្នុងមូលដ្ឋានរាជធានីខេត្ត អំពីគោលការណ៍របស់សម្តេចធិបតីណែនាំឱ្យក្រសួងមុខងារសាធារណៈអនុវត្តក្នុងការងារកំណែទម្រង់ក្នុងវិស័យមុខងារសាធារណៈរួមមាន៖(១).ការកែទម្រង់ការប្រឡងជ្រើសរើសមន្ត្រីរាជការតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព (២).ការពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់ដល់គុណភាពការងារប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព និង(៣).ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយ សង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។

ទន្ទឹមនឹងនេះ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានតម្រង់ទិសនិងណែនាំឱ្យអង្គប្រជុំដែលជាថ្នាក់ដឹកនាំក្រសួង និងមន្ទីរមុខងារសាធារណៈ រាជធានីខេត្តបន្តគាំទ្រ និងចូលរួមឱ្យសកម្មក្នុងការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ។

ស្របតាមរបៀបវារៈកិច្ចប្រជុំ ឯកឧត្តមរដ្ឋមន្ត្រី បានផ្តល់វេទិកាដល់ឯកឧត្តមរដ្ឋលេខាធិការប្រចាំការដើម្បីផ្សព្វផ្សាយផែនការការងារដែលបានរៀបចំនាពេលកន្លងមកនិងការងារបន្ថែមផ្សេងទៀតជាពិសេសលើការអនុវត្តក្របខណ្ឌរបស់មន្ត្រីរាជការស៊ីវិល និងជុំវិញការងារអាទិភាពក្នុងមុខងារសាធារណៈសម្រាប់ឆ្នាំ២០២៣ និងការងារកែទម្រង់វិស័យមុខងារសាធារណៈឆ្ពោះទៅទិសដៅអនាគត ដែលស្របជាមួយទស្សនវិស័យ និងការណែនាំរបស់ **សម្តេចមហាបវរធិបតី** ។

ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា

នៅព្រឹកថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា នៅវិមានសន្តិភាព។

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានតួនាទីសំខាន់ៗដូចជា៖ ដឹកនាំគាំទ្រ និងសម្របសម្រួលការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ រៀបចំនិងអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាលគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រៀបចំកម្មវិធីកែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល។ គណៈកម្មាធិការនេះក៏មានតួនាទីក្នុងការលើកសំណើជូនដល់រាជរដ្ឋាភិបាលអនុម័តលើគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រ និងផែនការសកម្មភាពបម្រើឱ្យការកែទម្រង់រដ្ឋបាលសាធារណៈជាដើម។

ក្នុងនីតិកាលនេះ ដើម្បីជំរុញការងារកែទម្រង់រដ្ឋបាលសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់នោះ រាជរដ្ឋាភិបាលបានរៀបចំព្រះរាជក្រឹត្យថ្មីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានចំនួន ២១ មាត្រា។ ព្រះរាជក្រឹត្យថ្មីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលកែសម្រួលថ្មីនេះ ត្រូវបានព្រះមហាក្សត្រត្រាស់បង្គាប់ឱ្យប្រើប្រាស់នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣។

ចំណុចសំខាន់ៗដែលបានកែសម្រួល គឺសមាសភាពរបស់ គ.ក.ស. មានបន្ថែមប្រធានអនុគណៈកម្មាធិការទាំង៤ នៃ គ.ក.ស. និងតំណាងនៃគណៈអភិបាលរាជធានី ខេត្ត ទាំង ២៥ ជាសមាជិក ព្រមទាំងកែសម្រួលអនុគណៈកម្មាធិការទាំង៤ នៃ គ.ក.ស. ដែលមានក្នុងព្រះរាជក្រឹត្យចាស់ឱ្យសមស្របតាមប្រភេទនិងទំហំការងារដែលគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈត្រូវទទួលបន្ទុក។

អនុគណៈកម្មាធិការទាំង៤ នៃ គ.ក.ស. មានដូចជា៖

១) អនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈ និងនវានុវត្តន៍
២) អនុគណៈកម្មាធិការឧត្តមភាពសេវាសាធារណៈ
៣) អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស
៤) អនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រី។

ការរៀបចំក្រុមការងារ នីតិវិធី និងបែបបទ ស្តីពី «ការជ្រើសរើសក្របខណ្ឌគ្រូបង្រៀនឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣»

(កិច្ចប្រជុំពិភាក្សា «ស្តីពីការរៀបចំក្រុមការងារ នីតិវិធី និងបែបបទ ស្តីពីការជ្រើសរើសក្របខណ្ឌគ្រូបង្រៀនឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣»)

ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាប្រចាំការក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពី «ការរៀបចំក្រុមការងារ នីតិវិធី និងបែបបទស្តីពីការជ្រើសរើសក្របខណ្ឌគ្រូបង្រៀនឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣» នាថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ ។

បន្ទាប់ពីធ្វើកិច្ចពិភាក្សា និងផ្តល់មតិយោបល់រួចមក ឯកឧត្តមប្រធានអង្គប្រជុំបានផ្តល់ជាប្រសាសន៍ណែនាំ និងឯកភាពលើការងាររួមមាន៖

១).សេចក្តីព្រាង សេចក្តីសម្រេចបង្កើតគណៈកម្មការប្រឡង

២).ការជ្រើសរើសគ្រូកីឡា

៣).ការផ្តល់ជូនក្របខណ្ឌដល់បេក្ខជនប្រឡងជាប់តាមគុណវុឌ្ឍិកម្រិត សិក្សា និងវិញ្ញាបនបត្រ

៤).វិញ្ញាសាប្រឡងសម្រាប់គ្រូបង្រៀនកម្រិតអនុវិទ្យាល័យ បឋមមត្តេយ្យ

៥).ការចុះឈ្មោះប្រឡងតាមប្រព័ន្ធអនឡាញសាលាភូមិន្ទរដ្ឋបាល។

ជាចុងបញ្ចប់ **ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ** បានគូសបញ្ជាក់ថាការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងក្របខណ្ឌត្រូវប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន ប្រសិទ្ធភាព។

ការរៀបចំនីតិវិធីប្រឡងប្រជែងជ្រើសរើសក្របខណ្ឌ មន្ត្រីរាជការស៊ីវិល របស់អង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់ ឆ្នាំ២០២៣

ក្រសួងមុខងារសាធារណៈ នាព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ បានដឹកនាំកិច្ចប្រជុំពិភាក្សាលើការរៀបចំនីតិវិធីប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិលនៃអង្គភាពប្រឆាំងអំពើពុករលួយចំនួន៣៣កន្លែងសម្រាប់ផែនការក្របខណ្ឌឆ្នាំ២០២៣ នៅបន្ទប់ប្រជុំទីស្តីការក្រសួង ដោយមានការអញ្ជើញចូលរួមពីរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ នាយករងសាលាភូមិន្ទរដ្ឋបាល និងអង្គភាពជំនាញនៃក្រសួងមុខងារសាធារណៈ តំណាងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងតំណាងរបស់អង្គភាពប្រឆាំងអំពើពុករលួយសរុបចំនួនប្រមាណ៣៥នាក់។

បន្ទាប់ពីធ្វើកិច្ចពិភាក្សា និងមតិផ្តល់យោបល់ពីអង្គប្រជុំរួចមក **ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ** បានថ្លែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងអនុវត្តភារកិច្ច និងការចូលរួមសហការដោយស្មារតីទទួលខុសត្រូវខ្ពស់ព្រមទាំងបានកំណត់លើរបៀបវារៈជាច្រើនរួមមាន៖

១. កំណត់សមាសភាពគណៈកម្មការប្រឡង
២. រៀបចំសេចក្តីជូនដំណឹងនៃការប្រឡងជ្រើសរើសតាមប្រភេទក្របខណ្ឌកម្រិតសិក្សា និងតាមតម្រូវការតាមអង្គភាព ឬទីកន្លែងត្រូវការជាក់ស្តែង
៣. កំណត់វិញ្ញាសារប្រឡងជ្រើសរើស
៤. រៀបចំបង្កើតគណៈកម្មការរៀបចំវិញ្ញាសារសម្រាប់ការប្រឡង
៥. រៀបចំបង្កើតអនុគណៈកម្មការ និងអ្នកសង្កេតការណ៍សម្រាប់ការប្រឡង
៦. កំណត់កាលបរិច្ឆេទប្រឡង ដើម្បីធានាការប្រឡងប្រព្រឹត្តទៅស្របតាមគោលការណ៍គុណធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាពដែលជាទស្សនវិស័យ និងគោលការណ៍កែទម្រង់ស្របតាមយុទ្ធសាស្ត្របញ្ចកោណ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ(គ.វ.ជ.) ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២២-២០២៣

ឯកឧត្តម ហ៊ុន ម៉ានី ដឹកនាំកិច្ចប្រជុំគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ(គ.វ.ជ.) ពិនិត្យវាយតម្លៃ ជ្រើសរើសសម្រាំង បេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឆ្នាំ២០២២-២០២៣

ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ(គ.វ.ជ.)បានដឹកនាំកិច្ចប្រជុំជាមួយសមាជិក និងក្រុមការងារបច្ចេកទេសនៃ គ.វ.ជ. ដើម្បីពិនិត្យវាយតម្លៃជ្រើសសម្រាំងបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឆ្នាំ២០២២-២០២៣ នាព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងមុខងារសាធារណៈ។

កិច្ចប្រជុំនេះដែរមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំ សមាជិក សមាជិកា គ.វ.ជ. ដែលមានសមាសភាពអន្តរក្រសួងពាក់ព័ន្ធរួមមាន ឯកឧត្តម លោកជំទាវ តំណាងក្រសួងមុខងារសាធារណៈ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សរុបអ្នកចូលរួមចំនួនប្រមាណ ៤៥នាក់។

ដោយឡែកសម្រាប់ឆ្នាំ២០២៣ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ តាមរយៈប្រកាសអន្តរក្រសួងស្តីពីការដាក់ឱ្យដំណើរការការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ បានកំណត់យកអនុវិទ្យាល័យ និងសាលាបឋមសិក្សាសម្រាប់វិស័យអប់រំ និងមណ្ឌលសុខភាពសម្រាប់វិស័យសុខាភិបាល ជាអង្គភាពផ្តល់សេវាសាធារណៈក្នុងការវាយតម្លៃឆ្នាំ២០២២-២០២៣។

បច្ចុប្បន្នការអនុវត្តដំណើរការការវាយតម្លៃ និងការទទួលស្គាល់បាននិងកំពុងឈានដល់ដំណាក់កាលជ្រើសរើសសម្រាំងបេក្ខភាពដើម្បីបន្តនីតិវិធីវាយតម្លៃបន្ទាប់មុនឈានដល់ដំណាក់កាលជ្រើសរើសជ័យលាភីនាពេលខាងមុខស្របតាមកាលបរិច្ឆេទកំណត់។

ការពិភាក្សាការងារកម្រិតថ្នាក់ដឹកនាំ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារកម្រិតថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិភាក្សា និងពិគ្រោះយោបល់លើរបៀបវារៈចំនួន៤ រួមមាន៖ ១-ការងារត្រូវអនុវត្តរបស់ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ២-ការបែងចែកភារកិច្ចជូន អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ៣-ការរៀបចំផែនការសកម្មភាព ឆ្នាំ២០២៤ និង៤-បញ្ហាផ្សេងៗ។

បន្ទាប់ពីកិច្ចពិភាក្សា និងការចូលរួមផ្តល់មតិយោបល់ពីអង្គប្រជុំរួចមក ឯកឧត្តមប្រធានបានផ្តល់ការណែនាំតម្រង់ទិសសម្រាប់ការងារជាអាទិភាពមួយចំនួន ដែលអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវអនុវត្ត។

ការពិភាក្សាការងាររបស់ក្រុមការងារបច្ចេកទេសទាំង៣ក្រុមនៃ គ.វ.រ. និងអនុគណៈកម្មាធិការទាំង៤នៃ គ.ក.ស.

ក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការណ៍គន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (គ.វ.រ.) និងអនុគណៈកម្មាធិការទាំង៤ នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.ស.) ប្រជុំពិភាក្សាការងារ

នៅរសៀលថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣ សាលប្រជុំ "តេជោសន្តិភាព" **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ក.ស. តំណាង **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានអនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. បានសម្របសម្រួលកិច្ចប្រជុំពិភាក្សាការងាររបស់ក្រុមការងារបច្ចេកទេសទាំង៣ក្រុមនៃ គ.វ.រ. និងអនុគណៈកម្មាធិការទាំង៤នៃ គ.ក.ស.ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីជាប្រធាន អនុប្រធាន និងសមាជិកក្រុមការងារ សរុបចំនួន៩០ រូប។

គោលបំណងនៃកិច្ចប្រជុំពិភាក្សានាពេលនេះគឺមានគោលបំណងសំខាន់ធំៗពីរ រួមមាន៖ (១)កំណត់អំពីរបៀបរបបបំពេញការងាររបស់ក្រុមការងារទាំងអស់ (២)កំណត់ការរៀបចំផែនការសកម្មភាពការងារផ្សារភ្ជាប់ថវិកាគាំទ្រសម្រាប់ឆ្នាំ២០២៤របស់ក្រុមនីមួយៗ ។ កិច្ចប្រជុំបានពិភាក្សា និងផ្តល់មតិយោបល់ជាធាតុចូល យ៉ាងច្រើនផុសផុល និងបានឯកភាពលើរបៀបរបបបំពេញការងាររបស់ក្រុមការងារ ព្រមទាំងកំណត់ពេលវេលាក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៤ របស់ក្រុមនីមួយៗ និងផ្តល់ជូនមកអគ្គលេខាធិការដ្ឋាន គ.ក.ស. នាពេលខាងមុខ ដើម្បីបូកសរុប និងគោរពស្នើសុំការពិនិត្យសម្រេចពី **ឯកឧត្តម រដ្ឋមន្ត្រី** ។

អង្គប្រជុំបានប្រព្រឹត្តទៅក្នុងស្មារតីជាក្រុមប្រកបដោយភាតរភាព សាមគ្គីភាព យោគយល់ និងប្រកបដោយស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមអនុវត្តការងារកែទម្រង់ទាំងក្នុងក្របខណ្ឌការងារកែទម្រង់រដ្ឋបាលសាធារណៈជារួម និងក្នុងក្របខណ្ឌការងារកែទម្រង់វិធានការគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧នៃរដ្ឋសភា។

ការចុះអនុវត្តលើការវាយតម្លៃជាក់ស្តែងដល់ទីតាំងបេក្ខភាពសាលាបឋមសិក្សារបស់ គណៈកម្មការបច្ចេកទេសអន្តរក្រសួង និងក្រុមការងារលេខាធិការដ្ឋាននៃ គ.វ.ជ.

(គណៈកម្មការបច្ចេកទេសអន្តរក្រសួងនៃ គ.វ.ជ. ចុះវាយតម្លៃដល់ទីតាំងជាក់ស្តែងដើម្បីស្វែងរកបេក្ខភាពសាលាបឋមសិក្សាគំរូក្នុងវិស័យអប់រំ ស្ថិតក្នុងខេត្តសៀមរាប)

ខេត្តសៀមរាប នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម ឆាយ ឆត្រាវុធ** រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈបានដឹកនាំគណៈកម្មការបច្ចេកទេសអន្តរក្រសួង និងក្រុមការងារលេខាធិការដ្ឋាន នៃ គ.វ.ជ. ចុះអនុវត្តការវាយតម្លៃជាក់ស្តែងដល់ទីតាំងបេក្ខភាព សាលាបឋមសិក្សានៅក្នុងខេត្តសៀមរាប។

ក្នុងដំណើរការវាយតម្លៃនេះមានការចូលរួមដោយលោកស្រីអភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប សមាជិកក្រុមប្រឹក្សាខេត្ត តំណាងមន្ទីរមុខងារសាធារណៈ តំណាងមន្ទីរអប់រំ យុវជន និងកីឡា តំណាងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងអភិបាល នៃគណៈអភិបាលក្រុង ស្រុក តំណាងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក គណៈកម្មការគ្រប់គ្រងសាលារៀន តំណាងរដ្ឋបាលឃុំ សង្កាត់ នាយក នាយករង នាយិការង លោកគ្រូ អ្នកគ្រូ និងមន្ត្រីជំនាញរដ្ឋបាលខេត្តសៀមរាប។

ការវាយតម្លៃនៅទីតាំងជាក់ស្តែងរបស់បេក្ខភាពសាលាបឋមសិក្សាខាងលើក្នុងគោលបំណងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យសាកសួរព័ត៌មានពីភាគីពាក់ព័ន្ធ និងវាយតម្លៃដាក់ពិន្ទុនៅទីតាំងជាក់ស្តែងរបស់បេក្ខភាពដោយមានការបែងចែកជាក្រុមគោលដៅដើម្បីធ្វើការវាយតម្លៃដោយផ្តោតលើលក្ខណៈវិនិច្ឆ័យគោលចំនួន៨ រួមមាន៖

១. ស្តង់ដាសេវាសាធារណៈ
២. ស្តង់ដាឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ
៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព
៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព
៥. ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព
៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ
៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍
៨. ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ។

កាលបរិច្ឆេទ សម្រាប់ការចុះវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ នៅទីតាំងជាក់ស្ដែងរបស់គ.វ.ជ. (ដំណាក់កាលវាយតម្លៃសម្រេចចុងក្រោយ) ចាប់ផ្ដើមពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ (សាលាបឋមសិក្សា និងអនុវិទ្យាល័យ)

ឈ្មោះ អ.ផ.ស	ក្រុង-ស្រុក-ខណ្ឌ	រាជធានី-ខេត្ត	កាលបរិច្ឆេទ
សាលាបឋមសិក្សា			
សាលាបឋមសិក្សា សំរោង	ក្រុង សំរោង	ខេត្ត ឧត្តរមានជ័យ	០៤/ធ្នូ/២០២៣
សាលាបឋមសិក្សា វត្តបូព៌	ក្រុង សៀមរាប	ខេត្ត សៀមរាប	០៥/ធ្នូ/២០២៣
សាលាបឋមសិក្សា ក្រវ៉ាន់	ក្រុង សៀមរាប	ខេត្ត សៀមរាប	០៦/ធ្នូ/២០២៣
សាលាបឋមសិក្សា អនុវត្តហ៊ុន	ស្រុក ស្ទឹងសែន	ខេត្ត កំពង់ធំ	១១/ធ្នូ/២០២៣
សាលាបឋមសិក្សា សម្ដេចជាស៊ីម	ក្រុង បាត់ដំបង	ខេត្ត បាត់ដំបង	១២/ធ្នូ/២០២៣
សាលាបឋមសិក្សា វត្តចែង	ស្រុក សង្កែ	ខេត្ត បាត់ដំបង	១៣/ធ្នូ/២០២៣
សាលាបឋមសិក្សា គិរីសុវណ្ណវង្ស	ស្រុក រលៀប្អៀរ	ខេត្ត កំពង់ឆ្នាំង	១៨/ធ្នូ/២០២៣
សាលាបឋមសិក្សា ស្វាយជ្រំ	ស្រុក ស្វាយជ្រំ	ខេត្ត ស្វាយរៀង	២១/ធ្នូ/២០២៣
សាលាបឋមសិក្សា អង្គជុំ	ស្រុក ជុំគិរី	ខេត្ត កំពត	២៥/ធ្នូ/២០២៣
សាលាបឋមសិក្សា ចតុមុខ	ខណ្ឌ ដូនពេញ	រាជធានីភ្នំពេញ	២៧/ធ្នូ/២០២៣
អនុវិទ្យាល័យ			
អនុវិទ្យាល័យ ពោធិ៍ចិនតុង	ខណ្ឌ ពោធិ៍សែនជ័យ	រាជធានីភ្នំពេញ	២៨/ធ្នូ/២០២៣
អនុវិទ្យាល័យ ទួលថ្ម	ក្រុង កំពង់ចាម	ខេត្ត កំពង់ចាម	០៣/មករា/២០២៤
អនុវិទ្យាល័យ អន្លង់អក	ស្រុក កងមាស	ខេត្ត កំពង់ចាម	០៤/មករា/២០២៤
អនុវិទ្យាល័យ ទីរួមខេត្ត	ក្រុង ច្បារមន	ខេត្ត កំពង់ស្ពឺ	០៨/មករា/២០២៤
អនុវិទ្យាល័យ លង្វែក	ស្រុក កំពង់ត្រឡាច	ខេត្ត កំពង់ឆ្នាំង	០៩/មករា/២០២៤
អនុវិទ្យាល័យ ភ្នំយ៉ាត	ក្រុង ប៉ៃលិន	ខេត្ត ប៉ៃលិន	១៥/មករា/២០២៤
អនុវិទ្យាល័យ បាក់អំរែក	ស្រុក ឯកភ្នំ	ខេត្ត បាត់ដំបង	១៦/មករា/២០២៤
អនុវិទ្យាល័យ ពោធិ៍សាត់	ក្រុង ពោធិ៍សាត់	ខេត្ត ពោធិ៍សាត់	១៧/មករា/២០២៤
អនុវិទ្យាល័យ សង្គមថ្មី	ស្រុក សង្គមថ្មី	ខេត្ត ព្រះវិហារ	២២/មករា/២០២៤
អនុវិទ្យាល័យ មិត្តភាពខ្មែរ-ជប៉ុន	ក្រុង សៀមរាប	ខេត្ត សៀមរាប	២៥/មករា/២០២៤

កាលបរិច្ឆេទសម្រាប់ការចុះវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យសុខាភិបាល នៅទីតាំងជាក់ស្តែងរបស់គ.ក.រ.
(ដំណាក់កាលវាយតម្លៃសម្រេចចុងក្រោយ)

ចាប់ផ្តើមពីថ្ងៃទី០៤ រហូតដល់ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣

(មណ្ឌលសុខភាព)

ឈ្មោះ អ.ផ.ស	ក្រុង-ស្រុក-ខណ្ឌ	រាជធានី-ខេត្ត	កាលបរិច្ឆេទ
មណ្ឌលសុខភាព តានី	ស្រុក អង្គរជ័យ	ខេត្ត កំពត	០៤/ធ្នូ/២០២៣
មណ្ឌលសុខភាព អង្គភ្នំតូច	ស្រុក អង្គរជ័យ	ខេត្ត កំពត	០៥/ធ្នូ/២០២៣
មណ្ឌលសុខភាព ព្រៃញ្ញៅ	ស្រុក ពារាំង	ខេត្ត ព្រៃវែង	០៨/ធ្នូ/២០២៣
មណ្ឌលសុខភាព ថ្មគ្រែ	ស្រុក ចិត្របុរី	ខេត្ត ក្រចេះ	១១/ធ្នូ/២០២៣
មណ្ឌលសុខភាព ស្ពឺ	ស្រុក ចំការលើ	ខេត្ត កំពង់ចាម	១៤/ធ្នូ/២០២៣
មណ្ឌលសុខភាព ពេជចង្វារ	ស្រុក បរិបូណ៌	ខេត្ត កំពង់ឆ្នាំង	១៨/ធ្នូ/២០២៣
មណ្ឌលសុខភាព សំរោង	ស្រុក ភ្នំក្រវាញ	ខេត្ត ពោធិ៍សាត់	២១/ធ្នូ/២០២៣
មណ្ឌលសុខភាព បឹងបត់កណ្តោល	ស្រុក បាកាន	ខេត្ត ពោធិ៍សាត់	២២/ធ្នូ/២០២៣
មណ្ឌលសុខភាព បុស្សរ	ស្រុក ព្រះនេត្រព្រះ	ខេត្ត បន្ទាយមានជ័យ	២៥/ធ្នូ/២០២៣
មណ្ឌលសុខភាព គោកចក	ក្រុង សៀមរាប	ខេត្ត សៀមរាប	២៨/ធ្នូ/២០២៣

ពិធីសំណេះសំណាលលើកដំបូងជាមួយសមាជិក សមាជិកា របស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ(គ.ក.ស.)

កិច្ចប្រជុំតម្រង់ទិសលើកដំបូងរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ(គ.ក.ស.)

នារសៀលថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣នៅសាលាភូមិន្ទរដ្ឋបាល **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានដឹកនាំកិច្ចប្រជុំលើកដំបូងដើម្បីជួបផ្ទាល់ជាមួយសមាជិក សមាជិការបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ(គ.ក.ស.) ក៏ដូចជាណែនាំតួនាទីភារកិច្ច និងតម្រង់ទិសការងារបន្ត។ កិច្ចប្រជុំនេះមានការចូលរួមពីអនុប្រធាន សមាជិក សមាជិកានៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតំណាងក្រសួងស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួនប្រមាណ ១២០នាក់។

ឯកឧត្តមរដ្ឋមន្ត្រី បានមានមតិស្វាគមន៍ និងបានតម្រង់ទិសដល់អង្គប្រជុំទាំងមូលដោយលើកឡើងថា៖ ក្រសួងមុខងារសាធារណៈ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលដែលកំពុងរៀបចំសកម្មភាពការកែទម្រង់រដ្ឋបាលសាធារណៈជាពិសេសក្រោមការចង្អុលបង្ហាញដោយផ្ទាល់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈការអនុវត្តនូវវិធានការគន្លឹះជាអាទិភាពចំនួន៣រួមមាន៖ ទី១.ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព ទី២.ការពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព និងទី៣.ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។ ក្នុងជំនួបដំបូងនៃគណៈកម្មការកែទម្រង់រដ្ឋបាលសាធារណៈ **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈបានរៀបរាប់ពីតួនាទីភារកិច្ចដែលមានចែងនៅក្នុងព្រះរាជក្រឹត្យជូនអង្គប្រជុំ។ក្រោយពីការរៀបរាប់រួចមកអង្គប្រជុំបានមានមតិយោបល់យ៉ាងផុសផុលដែលជាធាតុចូលយ៉ាងសំខាន់ជូនទៅដល់គណៈកម្មការសម្រាប់ការងារបន្ត។

ដោយបានឃើញមានការចូលរួមយ៉ាងផុសផុលរបស់សមាជិក សមាជិកា របស់គណៈកម្មការកែទម្រង់រដ្ឋបាលសាធារណៈ **ឯកឧត្តម រដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវដែលមានវត្តមានក្នុងអង្គប្រជុំនិងស្នើជំរុញចិត្តឱ្យចូលរួមគិតគូរធ្វើការជាមួយគ្នាជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភាដែលយើងទាំងអស់គ្នាត្រូវមានភារកិច្ចចូលរួមសម្រេចឱ្យបាននូវចក្ខុវិស័យដឹកនាំវែងឆ្ងាយដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងមុខងារសាធារណៈ ប្រជុំពិភាក្សាការងារ ជាមួយតំណាងធនាគារពិភពលោកប្រចាំនៅកម្ពុជា

ឯកឧត្តម គង់ សុភី រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយនឹងតំណាងធនាគារពិភពលោកនៅកម្ពុជា នាព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ នៅសាលាភូមិន្ទរដ្ឋបាល ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការដែលធនាគារពិភពលោកប្រចាំនៅកម្ពុជា បានជួយគាំទ្រជាជំនួយបច្ចេកទេសនាពេលកន្លងមក រួមមាន៖ ១. កម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ ២.ការពិនិត្យផ្តល់យោបល់លើឯកសារកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និង ៣.ការជួយរៀបចំផែនទីបង្ហាញផ្លូវសម្រាប់គម្រោង HRMIS។

ជាលទ្ធផលកិច្ចប្រជុំបានសម្រេចលើការងារចំនួន៣ សំខាន់ៗ រួមមាន៖ ១.សម្រាប់គម្រោងកម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងនវានុវត្ត នឹងត្រូវបញ្ចប់នៅខែមិថុនាឆ្នាំ២០២៤ ខាងមុខ ហើយនឹងត្រូវប្រគល់ជូនសាលាភូមិន្ទរដ្ឋបាលជាអ្នកបន្តអនុវត្តគម្រោង ២.សហការផ្តល់យោបល់លើឯកសារកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និង ៣.ការជួយរៀបចំផែនទីបង្ហាញផ្លូវសម្រាប់គម្រោង HRMIS តំណាងធនាគារពិភពលោកនៅកម្ពុជា នឹងពិនិត្យលទ្ធភាពជួយពិនិត្យនិងផ្តល់យោបល់ជាបន្តក្នុងរយៈពេលសមរម្យមួយនាពេលខាងមុខ។

ការបន្តពិនិត្យ និងពិភាក្សារៀបចំផែនការសកម្មភាពឆ្នាំ២០២៤ សម្រាប់ក្រុមការងារអនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

នាព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ នៅទីស្តីការក្រសួង **ឯកឧត្តម ជុក មុន្នី** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ បានដឹកនាំកិច្ចប្រជុំបន្តពិនិត្យ និងពិភាក្សារៀបចំផែនការសកម្មភាពឆ្នាំ២០២៤ សម្រាប់ក្រុមការងារអនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្សនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដោយមានការចូលរួមពីសំណាក់សមាជិកក្រុមការងារ សរុបអ្នកចូលរួមប្រមាណចំនួន ១៨នាក់។

បន្ទាប់ពីការពិភាក្សាផ្តល់មតិយោបល់ជាធាតុចូលជាច្រើនរួចមក អង្គប្រជុំបានឯកភាពលើការងារមួយចំនួនរួមមាន៖ ១)ការកំណត់យកចំនួនចង្កោមសកម្មភាពចំនួន០៦ និងសកម្មភាពរង ២)ការកំណត់ពេលវេលាក្នុងការអនុវត្ត ៣)រក្សាទុកស្ថានភាពធាតុចូលរបស់ក្រុមទាំង៣ ៤)ក្រុមការងារទាំង៣ត្រូវសិក្សាបន្តលើលិខិតបទដ្ឋានពាក់ព័ន្ធនានា ៥)កំណត់ការរៀបចំទម្រង់គំរូរបាយការណ៍នៅត្រីមាសទី១ ឆ្នាំ២០២៤ និង ៦)ការវិភាគស្ថាប័នលើរចនាសម្ព័ន្ធ និងបញ្ហាប្រឈម។

វឌ្ឍនភាពការងារក្រុមការងារបច្ចេកទេសទាំង៣ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្ត វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ (គ.វ.រ)

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការ និងជាអនុប្រធានប្រចាំការនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ** បានដឹកនាំកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសទាំង៣ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ (គ.វ.រ)។

ក្រុមការងារបច្ចេកទេសទាំង៣ រួមមាន៖

១-ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី

២-ក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ

៣-ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម។

ទន្ទឹមនឹងនេះ កិច្ចប្រជុំ ក៏បានពិភាក្សាការងារជុំវិញគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.ស) ផងដែរ។ សូមជម្រាបថា គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.ស) បានបែងចែកអនុគណៈកម្មការចំនួន៤ គឺ៖

១-អនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

២-អនុគណៈកម្មាធិការឧត្តមភាពសេវាសាធារណៈ នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

៣-អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្សនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និង

៤-អនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

កិច្ចប្រជុំប្រព្រឹត្តបានប្រព្រឹត្តទៅ នៅសាលាភូមិន្ទរដ្ឋបាល ដោយបានពិភាក្សា និងផ្តល់មតិយោបល់ផ្តោតសំខាន់ទៅលើរបៀបវារៈរួមមាន៖

១-សេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០២៤

២-ការគិតគូរអំពីការរៀបចំយន្តការប្រាក់ឧបត្ថម្ភលើកទឹកចិត្ត

៣-តម្រង់ទិសបន្ថែមផ្សេងៗ។

អង្គប្រជុំបានប្រព្រឹត្តទៅក្នុងស្មារតីជាក្រុមប្រកបដោយសាមគ្គីភាព យោគយល់ ស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមអនុវត្តការងារកែទម្រង់ទាំងក្នុងក្របខណ្ឌការងារកែទម្រង់រដ្ឋបាលសាធារណៈជារួម និងក្នុងក្របខណ្ឌការងារកែទម្រង់វិធានការគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧នៃរដ្ឋសភា។

កិច្ចប្រជុំរៀបចំផែនការសកម្មភាពឆ្នាំ២០២៤ សម្រាប់ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល

ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម នាយ ឆន្ទ្រាវុធ** រដ្ឋលេខាធិការ បានដឹកនាំកិច្ចប្រជុំរៀបចំផែនការសកម្មភាពឆ្នាំ២០២៤ សម្រាប់ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល។

កិច្ចប្រជុំនេះសម្រេចបានចំណុចសំខាន់ៗមួយចំនួនដូចជា៖ ១-សេចក្តីព្រាងផែនការសកម្មភាពរបស់ក្រុមការងារឆ្នាំ២០២៤ និងថវិកាគាំទ្រក្នុងការអនុវត្ត ២-ការកំណត់សូចនាករ ៣-ការរៀបចំយន្តការវាយតម្លៃសមិទ្ធកម្ម និង ៤-ការកំណត់កម្រិតការលើកទឹកចិត្តលើការវាយតម្លៃសមិទ្ធកម្ម។

ឯកឧត្តមប្រធានក្រុមការងារបានកោតសរសើរ និងវាយតម្លៃខ្ពស់ដល់សមាជិកទាំងអស់ក្នុងការអនុវត្តការងារកន្លងមក ព្រមទាំងជំរុញលើកទឹកចិត្តបន្តសហការរួមគ្នាអនុវត្តផែនការការងារនេះប្រកបដោយគុណភាព និងប្រសិទ្ធភាព ដើម្បីសម្រេចចក្ខុវិស័យក្រសួង និងរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

ពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

នាពេលរសៀលថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានបន្តជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈដែលមានការចូលរួមពីថ្នាក់ដឹកនាំ និងក្រុមការងារបច្ចេកទេសទាំង៣នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ និងអនុគណៈកម្មាធិការទាំង៤នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈព្រមទាំងថ្នាក់ដឹកនាំពាក់ព័ន្ធនៅសាលាភូមិន្ទរដ្ឋបាល។ កិច្ចជំនួបនារសៀលនេះមានគោលបំណងដើម្បីសំណេះសំណាលឈ្វេងយល់ពីគ្នាទៅវិញទៅមកក៏ដូចជាការស្តាប់របាយការណ៍ការចែករំលែកនូវបទពិសោធន៍ព្រមទាំងជាឱកាសសម្រាប់ការលើកឡើងនូវបញ្ហាប្រឈមដែលក្រុមការងារបានជួបប្រទះកន្លងមកដើម្បីសិក្សានិងស្វែងរកដំណោះស្រាយជាមួយគ្នាហើយឆ្លើយតបជាមួយនឹងការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧។

បន្ថែមពីនេះអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (អ.គ.ក.ស.) មានតួនាទីជាសេនាធិការជូន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.ស.) និងមានភារកិច្ចដូចតទៅ៖

- គាំទ្រការអនុវត្តមុខងាររបស់អនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍ អនុគណៈកម្មាធិការឧត្តមភាពសេវាសាធារណៈ អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស និងអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរបស់ គ.ក.ស.
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ

- សម្របសម្រួលការងារប្រចាំថ្ងៃ និងបំពេញការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងផ្នែកភស្តុភារ ក្រោមកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ផ្តល់យោបល់ និងលើកសំណើដោះស្រាយជូន គ.ក.ស. លើបញ្ហាប្រឈម និងបញ្ហាជំនាញបច្ចេកទេសដើម្បីជំរុញល្បឿន និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីជាតិ
- សហការ និងសម្របសម្រួលជាមួយអង្គភាពនានាក្រោមឱវាទរបស់ក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍគ្រប់អង្គភាព និងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយសម្រាប់ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ តាមការចង្អុលបង្ហាញរបស់ គ.ក.ស.
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាលជាពិសេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- អនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន គ.ក.ស.

ឯកឧត្តមរដ្ឋមន្ត្រីបានមានប្រសាសន៍ជំរុញទឹកចិត្តឱ្យអង្គប្រជុំ **"យើងពិតជាមានឆន្ទៈក្នុងការកែទម្រង់ពិតប្រាកដណាស់ ហើយយើងសុទ្ធតែជាអ្នកចូលរួមមួយផ្នែកស្មើៗគ្នាក្នុងការជំរុញ និងការធ្វើទំនើបកម្មនៃប្រព័ន្ធមុខងារសាធារណៈកែប្រែចក្ខុវិស័យរបស់ សម្តេចមហាបវរធិបតី ជាសមិទ្ធផលដើម្បីបន្សល់ទុកដល់អ្នកជំនាន់ក្រោយ"។**

កិច្ចពិភាក្សាក្រុមការងារបច្ចេកទេសពិនិត្យការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងមុខងារសាធារណៈ ដើម្បីជំរុញដល់ការអនុវត្តគោលនយោបាយគន្លឹះរបស់រាជរដ្ឋាភិបាល

នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ នៅសាលាភូមិន្ទរដ្ឋបាល **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងមុខងារសាធារណៈ បានដឹកនាំកិច្ចប្រជុំបច្ចេកទេសពិនិត្យការងារចំនួន២៖ ១.ពិនិត្យលើការងារសមាហរណកម្ម ផ្ទេរបុគ្គលិកសិក្សានៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ២.ពិនិត្យពិភាក្សាលើសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីលក្ខខណ្ឌលក្ខណៈវិនិច្ឆ័យ យន្តការ និងនីតិវិធីនៃការតែងតាំងនាយក នាយករង នាយិកា នាយិការង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងបឋមសិក្សាសាធារណៈ។

កិច្ចប្រជុំនេះមានការចូលរួមពី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក ថ្នាក់ដឹកនាំ ជាអនុប្រធាន សមាជិកនៃគណៈកម្មការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងប្រធានមន្ទីរមុខងារសាធារណៈរាជធានី-ខេត្ត សរុបចំនួនប្រមាណ ៨០នាក់។

អង្គប្រជុំបានរាយការណ៍ពីវឌ្ឍនភាពការងារសមាហរណកម្ម ផ្ទេរបុគ្គលិកសិក្សានៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និង គ្រឹះស្ថានបឋមសិក្សាសាធារណៈ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងដាក់វេទិកាជូនប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្តរាយការណ៍ពីស្ថានភាពទូទៅ និងបញ្ហាប្រឈមដែលក្រុម ការងារថ្នាក់ក្រោមជាតិ បានជួបប្រទះផ្ទាល់ក្នុងពេលអនុវត្តការងារ ជាក់ស្តែង ព្រមទាំងអង្គប្រជុំបានមានមតិយោបល់ដោយសន្តិវិធី ប្រកបដោយភាពទន់ភ្លន់ជាច្រើន ដែលជាធាតុចូលដ៏ល្អក្នុង ការជួយគិត ជួយដោះស្រាយការងារចំពោះមុខនិងបញ្ហាដែលបាន ជួបពីអង្គប្រជុំទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ឯកឧត្តមប្រធាន អង្គប្រជុំ បានសម្រេចឯកភាពលើការងារមួយចំនួនរួមមាន៖ ១.ការបើកបៀវត្ស ដោយរក្សាតាមស្ថានភាពបច្ចុប្បន្ន ដែល បានបែងចែកតាមក្រុង ស្រុក ខណ្ឌ ដែលមានស្រាប់ ២.មិន អនុញ្ញាតឱ្យមានការផ្ទេរទេ និង ៣.កំណត់ដីកា ត្រូវចេញតាម សាលាដែលទទួលស្គាល់ដោយនាយក ឬនាយិកាស្របតាម លក្ខខណ្ឌត្រឹមត្រូវ និងចំនួនមន្ត្រីជាក់ស្តែងពិតប្រាកដមែន។ កិច្ចប្រជុំបានកំណត់ឱ្យក្រុមការងារត្រៀមរៀបចំកិច្ចប្រជុំបន្ទាន់ មួយ ដែលមានការចូលរួមពីក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួង អប់រំ យុវជន និងកីឡា ប្រជុំពិភាក្សាលើការកំណត់ទម្រង់ ជំរឿនមន្ត្រី ការចុះត្រួតពិនិត្យជាក់ស្តែង និងការធ្វើរបាយការណ៍។

ទន្ទឹមនឹងនេះ អង្គប្រជុំ ក៏បានពិនិត្យពិភាក្សា ផ្តល់ យោបល់ និងកែសម្រួលទៅលើសេចក្តីព្រាងសេចក្តីណែនាំ អន្តរក្រសួង ស្តីពីលក្ខខណ្ឌលក្ខណៈវិនិច្ឆ័យ យន្តការ និងនីតិ វិធីនៃការតែងតាំងនាយក នាយករង នាយិកា នាយិការង នៃ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងបឋមសិក្សាសាធារណៈ ដោយកំណត់កែសម្រួល រួមមាន៖ ១.រៀបចំលក្ខខណ្ឌលក្ខណៈ វិនិច្ឆ័យ ញែកឱ្យដាច់ដោយឡែកទៅតាមកម្រិតបឋមសិក្សា និង មត្តេយ្យ សិក្សា និងទៅតាមនាយក នាយករង នាយិកា នាយិការង ២.កំណត់គណៈកម្មការវាយតម្លៃ ញែកឱ្យដាច់ ដោយឡែកទៅតាមកម្រិត ៣.កំណត់បេក្ខភាពយកសាលាផ្ទាល់ ឬសាលាដទៃនៅក្នុងស្រុកតែមួយ ៤.កំណត់សមាសភាពគណៈ កម្មការ ៥.ពិនិត្យនីត្យានុគោលភាពជាមុនសិន និង ៦.សេចក្តី សម្រេច ត្រូវចុះហត្ថលេខាអន្តរក្រសួងចំនួនបី(ក្រសួងមុខងារ សាធារណៈ ក្រសួងមហាផ្ទៃ និងក្រសួងអប់រំ យុវជន និង កីឡា)។

ការវាយតម្លៃ និងពិនិត្យឡើងវិញលើដំណើរការនៃការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣ ចំនួន២៥០កន្លែង ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែងបានដឹកនាំកិច្ចប្រជុំ ស្តីពីការវាយតម្លៃ និងពិនិត្យឡើងវិញលើដំណើរការនៃការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្ម ឃុំ ឆ្នាំ២០២៣ ចំនួន២៥០កន្លែង ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ កិច្ចប្រជុំប្រព្រឹត្តទៅនៅសាលាភូមិន្ទរដ្ឋបាល ដោយមានការចូលរួមពីរដ្ឋលេខាធិការប្រចាំការ អនុរដ្ឋលេខាធិការ ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ជាប្រធាន អនុប្រធាន និងសមាជិក នៃអនុគណៈកម្មការរៀបចំការប្រឡងប្រជែង និងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងតំណាងអង្គភាពប្រឆាំងអំពើពុករលួយ។ កិច្ចប្រជុំនាថ្ងៃនេះ ជាការពិនិត្យវាយតម្លៃ និងពិភាក្សា ដើម្បីជាមូលដ្ឋានឈានដល់ការរៀបចំនិយាមនៃការប្រឡងប្រជែងទៅថ្ងៃអនាគត ដោយពិភាក្សាលើប្រធានបទសំខាន់ៗ សំដៅដល់ការរៀបចំដំណើរការនៃការប្រឡងឱ្យបានកាន់តែរលូន និងដើម្បីផ្តល់ភាពយុត្តិធម៌ ភាពងាយស្រួលដល់បេក្ខជនដែលចូលរួមប្រឡងប្រជែង ទាំងពេលវេលាសម្រាប់ការផ្សព្វផ្សាយការបង់វិភាគទាន និងការងារសម្របសម្រួលផ្សេងៗទៀត។

លទ្ធផលដ៏ជោគជ័យនៃការរៀបចំការប្រឡងប្រជែងមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣ ឈរលើគោលការណ៍គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ហើយការប្រឡងជាលើកដំបូងសម្រាប់អាណត្តិទី៧ នៃរដ្ឋសភានេះ ទទួលបានការសាទរ និងកោតសរសើរពីសំណាក់ថ្នាក់ដឹកនាំ និងមជ្ឈដ្ឋានមហាជន រួមទាំងបេក្ខជនគួរជាទីមោទនៈ។

សូមជម្រាបថា អង្គប្រជុំបានរាយការណ៍ និងលើកមតិយោបល់យ៉ាងផុសផុល ក៏ដូចជាបញ្ហាប្រឈមដែលបានជួបប្រទះក្នុងពេលបំពេញការងារជាក់ស្ដែងពីតំណាងក្រសួង អង្គភាព និងប្រធាន អនុប្រធាន អនុគណៈកម្មការនានា ទាំងដំណើរការមុនការប្រឡង ពេលប្រឡង និងក្រោយការប្រឡង សម្រាប់ជាធាតុចូលក្នុងការរៀបចំការប្រឡងប្រជែងនៅពេលខាងមុខទៀត។

ការពិនិត្យ ពិភាក្សាលើការផ្ទេរមុខងារ លើវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

នៅព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ នៅទីស្តីការក្រសួងមុខងារសាធារណៈ ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអនុប្រធាន សមាជិកនៃគណៈកម្មការកំណែទម្រង់រមជ្ឈការ និងវិសហមជ្ឈការ ដែលមានសមាសភាពចូលរួមពី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក និងថ្នាក់ដឹកនាំរបស់ក្រសួងមុខងារសាធារណៈ ព្រមទាំងតំណាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ សរុបប្រមាណ ៦០នាក់។

ឯកឧត្តមប្រធាន បានរម្លឹកពីរបាយការណ៍វឌ្ឍនភាពការងារនៃកិច្ចប្រជុំពិភាក្សាកន្លងមក និងមានប្រសាសន៍តម្រង់ទិសជូនអង្គប្រជុំពីកិច្ចការងារដែលនឹងត្រូវពិភាក្សាក្នុងការអនុវត្តបន្ត ទៅលើរបៀបវារៈទាំង២ រួមមាន៖

១.ពិនិត្យលើការងារសមាហរណកម្ម ផ្ទេរបុគ្គលិកសិក្សានៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

២.ពិនិត្យពិភាក្សាលើសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីលក្ខខណ្ឌ លក្ខណៈវិនិច្ឆ័យ យន្តការ និងនីតិវិធីនៃការតែងតាំងនាយក នាយិកា នាយករង នាយិការង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងបឋមសិក្សាសាធារណៈ។

អង្គប្រជុំបានចូលរួមផ្តល់ជាមតិយោបល់ជាធាតុចូលជាច្រើនពីតំណាងក្រសួង-ស្ថាប័ន នីមួយៗក៏បានរាយការណ៍ពីស្ថានភាពរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈម និងឯកភាពទៅលើចំណុចសំខាន់ៗ រួមមាន៖

១)កំណត់ចំនួននៃការផ្ទេរបុគ្គលិកសិក្សា មត្តេយ្យ និងបឋមទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

២)នីតិវិធីនៃការផ្ទេរបុគ្គលិកសិក្សា

៣)នីតិវិធីនៃការគ្រប់គ្រងស្ថានភាពគ្រូបង្រៀនថ្នាក់ក្រោមជាតិ

៤)នីតិវិធីនៃការបើកប្រាក់បៀវត្សជូនគ្រូបង្រៀន

៥)នីតិវិធីនៃការចេញដីការបស់ក្រុង ស្រុក

៦)ទម្រង់នៃការតែងតាំង និងលក្ខខណ្ឌនៃការតែងតាំង និង

៧)យន្តការអនុលោម និងនីត្យានុកូលភាព។

ការពិនិត្យសេចក្តីព្រាងផែនការសកម្មភាពជាយុទ្ធសាស្ត្ររបស់ក្រុមការងារបច្ចេកទេសទាំង៣ក្រុម នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ.

នៅរសៀលថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានអនុគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (គ.វ.រ.) បានដឹកនាំកិច្ចប្រជុំដើម្បីពិនិត្យ សេចក្តីព្រាងផែនការសកម្មភាពជាយុទ្ធសាស្ត្ររបស់ក្រុមការងារបច្ចេកទេសទាំង៣ក្រុម នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ. ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងសមាជិកក្រុមការងារបច្ចេកទេសទាំង៣ក្រុម របស់អនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ. និងអនុគណៈកម្មាធិការទាំង៤ នៃ គ.ក.ស. សរុបចំនួន ៦៥ រូប។

គោលបំណងនៃកិច្ចប្រជុំពិភាក្សានាពេលនេះគឺដើម្បីពិនិត្យសេចក្តីព្រាងផែនការសកម្មភាពជាយុទ្ធសាស្ត្ររបស់ក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ.។

កិច្ចប្រជុំបានប្រព្រឹត្តទៅតាមរយៈការធ្វើបទបង្ហាញ និងការរាយការណ៍អំពីសេចក្តីព្រាងផែនការសកម្មភាពជាយុទ្ធសាស្ត្រ ដោយប្រធានក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ. ព្រមទាំងកិច្ចពិភាក្សានិងការផ្តល់យោបល់ដើម្បីធ្វើការកែសម្រួលផែនការសកម្មភាពជាយុទ្ធសាស្ត្រដែលបានដាក់ចេញជាសេចក្តីព្រាងនេះ។

ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ បានណែនាំ និងធ្វើការតម្រង់ទិសបន្ថែមដល់ក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ. ដើម្បីធ្វើយ៉ាងណារៀបចំផែនការសកម្មភាពឱ្យឆ្លើយតប ទៅនឹងវិធានការគន្លឹះទាំង៣ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលដែលរួមមាន ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារ ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន និងការរៀបចំប្រព័ន្ធលើកទឹកចិត្ត គាំទ្រ ផ្អែកលើសមិទ្ធិកម្ម ព្រមទាំងឆ្លើយតបទៅនឹងការគាំទ្រ ដល់ការកែទម្រង់លើវិធានការគន្លឹះក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលផងដែរ ។

អង្គប្រជុំបានប្រព្រឹត្តទៅក្នុងស្មារតីជាក្រុមប្រកបដោយភាតរភាព សាមគ្គីភាព យោគយល់ និងប្រកបដោយស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមអនុវត្តការងារកែទម្រង់វិធានការគន្លឹះរបស់ រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៧ នៃរដ្ឋសភា។

ការដឹកនាំគណៈកម្មការបច្ចេកទេសអន្តរក្រសួង និងក្រុមការងារលេខាធិការដ្ឋាននៃ គ.វ.ជ. ចុះអនុវត្តការវាយតម្លៃនៅទីតាំងដាក់ស្តែង

ឯកឧត្តម ឆាយ ឆត្រាវុធ រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ និង **ឯកឧត្តម សៀត វិចិត្រ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ នៃក្រសួងមុខងារសាធារណៈ បានដឹកនាំគណៈកម្មការបច្ចេកទេសអន្តរក្រសួងនិងក្រុមការងារលេខាធិការនៃ គ.វ.ជ. ចុះអនុវត្តការវាយតម្លៃនៅទីតាំងដាក់ស្តែងបេក្ខភាពអនុវិទ្យាល័យនៅតាមបណ្តារាជធានី ខេត្ត ស្របតាមកាលបរិច្ឆេទដូចតទៅ៖

កាលបរិច្ឆេទ	ដឹកនាំដោយ	បេក្ខភាព អនុវិទ្យាល័យ រាជធានី ខេត្ត
ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣	ឯកឧត្តម ឆាយ ឆត្រាវុធ	អនុវិទ្យាល័យ ក្នុងរាជធានីភ្នំពេញ
ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៤		អនុវិទ្យាល័យ ក្នុងក្រុងកំពង់ចាម ខេត្តកំពង់ចាម
ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤		អនុវិទ្យាល័យ ក្នុងក្រុងច្បារមន នៃខេត្តកំពង់ស្ពឺ
ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤		អនុវិទ្យាល័យ ក្នុងស្រុកកំពង់ត្រឡាច នៃខេត្តកំពង់ឆ្នាំង
ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤		អនុវិទ្យាល័យ ក្នុងស្រុកសង្គមថ្មី នៃខេត្តព្រះវិហារ
ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤		អនុវិទ្យាល័យ ក្នុងក្រុងសៀមរាប ខេត្តសៀមរាប
ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤	ឯកឧត្តម សៀត វិចិត្រ	អនុវិទ្យាល័យ ក្នុងក្រុងប៉ៃលិន នៃខេត្តប៉ៃលិន
ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤		អនុវិទ្យាល័យ ក្នុងស្រុកឯកភ្នំ នៃខេត្តបាត់ដំបង

ការវាយតម្លៃនៅទីតាំងជាក់ស្តែងរបស់បេក្ខភាពអនុវិទ្យាល័យ ក្នុងគោលបំណងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យសាកស្សួរព័ត៌មានពីភាគីពាក់ព័ន្ធ និងវាយតម្លៃជាក់ពិន្ទុនៅទីតាំងជាក់ស្តែងរបស់បេក្ខភាព ដោយមានការបែងចែកជាក្រុមគោលដៅដើម្បីធ្វើការវាយតម្លៃដោយផ្តោតលើលក្ខណៈវិនិច្ឆ័យគោលចំនួន៨ រួមមាន៖ ១.ស្តង់ដាសេវាសាធារណៈ ២.ស្តង់ដា ឬ និយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ ៣.ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព ៤.ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព ៥.ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព ៦.ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ ៧.ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍ និង៨.ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ។

ជាលទ្ធផល ដោយសារមានការសហការយ៉ាងល្អពីគ្រប់ភាគីពាក់ព័ន្ធ គណៈកម្មការបច្ចេកទេសអន្តរក្រសួង នៃ គ.វ.ជ. បានធ្វើការចុះវាយតម្លៃជាក់ស្តែងដល់ទីតាំង បានបញ្ចប់ដោយជោគជ័យ និងប្រកបដោយបរិយាកាសរីករាយ។

ការពិនិត្យ និងតម្រង់ទិសការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់ក្រសួងមុខងារសាធារណៈ

នារសៀលថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** បានជួបជាមួយគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួងមុខងារសាធារណៈ ដើម្បីប្រជុំពិនិត្យ និងតម្រង់ទិសការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងមុខងារសាធារណៈ។

- ដឹកនាំ សម្របសម្រួលកិច្ចដំណើរការនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យមុខងាសាធារណៈ
- ដឹកនាំ សម្របសម្រួលនិងគាំទ្រដល់ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យមុខងារសាធារណៈ និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ
- ដឹកនាំ សម្របសម្រួលនិងគាំទ្រដល់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តសកម្មភាពកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្របតាមផែនការ សកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រសួងមុខងារសាធារណៈ
- ដឹកនាំ សម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យឬកិច្ចការអាទិភាព របស់ក្រសួងមុខងារសាធារណៈ។

- តាមដាន ត្រួតពិនិត្យជាប្រចាំលើការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យមុខងារសាធារណៈ ស្របតាមសេចក្តីសម្រេចរួម ដែលបានឯកភាពគ្នារវាងក្រសួងមុខងារសាធារណៈ ជាមួយនឹងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ របស់ គ.ជ.អ.ប.

- រៀបចំបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈម នៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងមុខងារសាធារណៈ ដើម្បីផ្ញើជូន គ.ជ.អ.ប តាមកាលកំណត់។

ជំនួបនេះ **ឯកឧត្តម ថោ សេដ្ឋាណា រដ្ឋលេខាធិការ** បានរាយការណ៍សង្ខេបពីសាវតារ ទិសដៅការងារ និងខ្លឹមសារសេចក្តីសម្រេច ព្រមទាំងលិខិតូបករណ៍នានាពាក់ព័ន្ធនឹងការងារវិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួងមុខងារសាធារណៈ។ បន្ទាប់មក អង្គប្រជុំបានបញ្ចេញមតិយោបល់ទៅលើបញ្ហាក្នុងការអនុវត្តការងារជាក់ស្តែងនាពេលកន្លងមកសម្រាប់ជាធាតុចូលក្នុងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាចុងបញ្ចប់ **ឯកឧត្តមរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ដោយកោតសរសើរលទ្ធផលការងារកន្លងមក និងជំរុញទឹកចិត្តឱ្យក្រុមការងារបន្តអនុវត្តការងារបន្ថែមទៀត ដោយយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តការងារស្នូលរបស់ខ្លួនផង និងពិនិត្យតាមដានវាយតម្លៃនូវបញ្ហាដែលកើតឡើងផង ដើម្បីរម្លឹក ឬរៀបចំប្រជុំពិគ្រោះយោបល់ក្នុងការដោះស្រាយបញ្ហាជាបន្ទាន់។ ឯកឧត្តមរដ្ឋមន្ត្រី ក៏បានស្នើឱ្យថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ រួមផ្សំជាមួយនឹងយន្តការក្រសួងមុខងារសាធារណៈ ដែលជាស្នូលនៃក្រសួងផង និងគណៈកម្មការកែទម្រង់រដ្ឋបាលសាធារណៈផង ព្រមទាំងគណៈកម្មការជាតិជំរុញកិច្ចការគន្លឹះផង សូមខិតខំប្រឹងប្រែងបំពេញការងារជាមួយគ្នា និងប្រទាក់ក្រឡាគ្នា ដើម្បីសម្រេចនូវគោលបំណងចម្បងៗរបស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ។

ជំនួបនេះបានប្រព្រឹត្តទៅនៅទីស្តីការក្រសួងមុខងារសាធារណៈ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គលេខាធិការ អគ្គាធិការ លោក លោកស្រីជាអគ្គាធិការរង អគ្គនាយករង ប្រធាននាយកដ្ឋាន និងថ្នាក់ដឹកនាំពាក់ព័ន្ធ។

ការប្រជុំពិភាក្សាការងារផ្ទៃក្នុង
អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈបានដឹកនាំកិច្ចប្រជុំពិភាក្សាការងារផ្ទៃក្នុង ដោយអ្នកចូលរួមសរុបចំនួន៤៥រូប។

បន្ទាប់ពីបង្ហាញពីតួនាទីនិងភារកិច្ចស្នូលរបស់ អ.គ.ក.ស. នៅក្នុងយន្តការនៃការអនុវត្តវិធានការគន្លឹះរាជរដ្ឋាភិបាលនិងការងារកែទម្រង់រដ្ឋបាលសាធារណៈរួចមក ឯកឧត្តមប្រធានកិច្ចប្រជុំបានណែនាំតម្រង់ទិសដល់នាយកដ្ឋាននីមួយៗត្រូវបន្តអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាព ទាន់ពេលវេលា ដោយមានការបែងចែកភារកិច្ចច្បាស់លាស់ ព្រមទាំងបន្តពង្រឹងការគ្រប់គ្រងវត្តមានមន្ត្រីឱ្យបានល្អ ជាពិសេសត្រូវគិតគូររៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពមន្ត្រី ដើម្បីឆ្លើយតបនឹងការងារជាក់ស្តែង។ ឯកឧត្តមអគ្គលេខាធិការក៏បានណែនាំនាយកដ្ឋានកិច្ចការទូទៅត្រូវសិក្សារៀបចំប្រព័ន្ធគ្រប់គ្រងឯកសារ និងទិន្នន័យរបស់ អ.គ.ក.ស. តាមបែបឌីជីថលសម្រាប់ប្រើប្រាស់នាពេលអនាគត។

ការពិនិត្យវឌ្ឍនភាពការងារប្រឡងប្រជែងជ្រើសរើសក្របខណ្ឌគ្រូបង្រៀន ឯកទេសអប់រំកាយ និងកីឡា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣ និងការត្រៀមរៀបចំការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌរបស់ក្រសួង-ស្ថាប័នដទៃទៀត

ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ គណៈកម្មការរៀបចំការប្រឡងប្រជែង ដឹកនាំដោយ **ឯកឧត្តម យក់ ម៉ុនណា រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ និងជាអនុប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែង** បានដឹកនាំកិច្ចប្រជុំពិភាក្សាលើការពិនិត្យវឌ្ឍនភាពការងារប្រឡងប្រជែងជ្រើសរើសក្របខណ្ឌគ្រូបង្រៀន ឯកទេសអប់រំកាយ និងកីឡា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣ និងការត្រៀមរៀបចំការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌរបស់ក្រសួង-ស្ថាប័នដទៃទៀត នៅទីស្តីការក្រសួងមុខងារសាធារណៈ។

កិច្ចប្រជុំពិភាក្សានិងឯកភាពលើវឌ្ឍនភាពការងាររួមមាន៖

១.នីតិវិធីនៃការរៀបចំបញ្ជីឈ្មោះបេក្ខជនប្រឡងឱ្យបានត្រឹមត្រូវច្បាស់លាស់

២.ការត្រៀមរៀបចំការផ្គត់ផ្គង់លើដំណើរការប្រឡង

៣.ការកំណត់ដំណើរការវិញ្ញាសាប្រឡង និងការធ្វើកំណែប្រឡង

៤.ការកំណត់យកទីតាំងមណ្ឌលប្រឡង

៥.ការរៀបចំយន្តការក្នុងការអនុវត្ត និងការទទួលខុសត្រូវរបស់គណៈកម្មការនីមួយៗ

៦.ការរៀបចំយន្តការនៃការស្រង់ និងដាក់ពិន្ទុរដល់បេក្ខជនប្រឡង

៧.ការបង្កើតសេចក្តីសម្រេចទទួលស្គាល់ថ្មីរបស់គណៈកម្មការ និងអនុគណៈកម្មការដោយបញ្ជាបយេនឌ័រជាប្រធានឬអនុប្រធាន

៨.ការរៀបចំស្នើសុំគោលការណ៍ ស្តីពីការជ្រើសរើសយកគ្រូបង្រៀនធ្វើជាអនុរក្សក្នុងការប្រឡងជ្រើសរើស។

សូមបញ្ជាក់ថា៖ គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣ លើក្របខណ្ឌគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា នឹងបើកកិច្ចប្រជុំបន្តជាលក្ខណៈអន្តរក្រសួង ក្នុងនោះរួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយ ដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខនេះ។

ការពិនិត្យវឌ្ឍនភាពការងារ និងពិភាក្សាផែនការសកម្មភាពឆ្នាំ២០២៤ ព្រមទាំងបែងចែកតួនាទីភារកិច្ចរបស់ក្រុមការងារអនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍

ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម គង់ សុធី** រដ្ឋលេខាធិការ បានដឹកនាំកិច្ចប្រជុំក្រុមការងារអនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍ ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងពិភាក្សាផែនការសកម្មភាពឆ្នាំ២០២៤ ព្រមទាំងបែងចែកតួនាទីភារកិច្ចក្នុងក្រុមការងារ។

អង្គប្រជុំបានពិនិត្យពិភាក្សាកែសម្រួលលើសកម្មភាព និងសកម្មភាពរង ចំនួន៣ រួមមានៈ ១.ការធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានស្ដីពីការផ្ដល់សេវាសាធារណៈថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ២.រៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីសេវាសាធារណៈ និង៣.សិក្សាស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនិងស្ថានភាពអនុវត្តស្ដីពីការជ្រើសរើសឬជួលអង្គភាពខាងក្រៅ ដើម្បីផ្ដល់សេវាបច្ចេកទេសឬសេវាទូទៅដល់ក្រសួង ស្ថាប័ន។

ឯកឧត្តមប្រធានបានស្នើឱ្យក្រុមការងារត្រៀមបែងចែកក្រុមតូចៗទទួលភារកិច្ចតាមគម្រោងផែនការសកម្មភាពនិងរៀបចំឱ្យមានការលើកទឹកចិត្តចំពោះសមិទ្ធផលការងារជាក់ស្ដែង ព្រមទាំងជំរុញពន្លឿនបញ្ចប់ការរៀបចំផែនការសកម្មភាពឱ្យបានទាន់ពេលវេលាកំណត់របស់អគ្គលេខាធិការដ្ឋាន គ.ក.ស. ដើម្បីរៀបចំបូកសរុបដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច។

ការពិភាក្សាលើការងារប្រឡងប្រជែងជ្រើសរើសក្របខណ្ឌគ្រូបង្រៀន ឯកទេសអប់រំកាយ និងកីឡា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣

នារសៀលថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម យក់ ម៉ុនណា** **រដ្ឋលេខាធិការប្រចាំការ និងជាអនុប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែងនៃក្រសួងមុខងារសាធារណៈ** បានដឹកនាំកិច្ចប្រជុំ ពិភាក្សាលើការងារប្រឡងប្រជែងជ្រើសរើសក្របខណ្ឌគ្រូបង្រៀន ឯកទេសអប់រំកាយ និងកីឡា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០២៣។ កិច្ចប្រជុំនេះ បានធ្វើវឌ្ឍនភាពការងារ និងបានកំណត់នីតិវិធីការងារមួយចំនួន ជាមួយក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំជារបាយការណ៍ដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច ឈានឆ្ពោះទៅកាន់ការប្រឡងនាពេលឆាប់ៗនេះ។

សូមបញ្ជាក់ផងដែរថា កិច្ចប្រជុំខាងលើ បានប្រព្រឹត្តទៅនៅសាលាភូមិន្ទរដ្ឋបាល ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ និងអង្គភាពជំនាញ នៃក្រសួងមុខងារសាធារណៈ នាយករងសាលាភូមិន្ទរដ្ឋបាល និងថ្នាក់ដឹកនាំមកពីតំណាងក្រសួង-ស្ថាប័ន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយ សរុបមានចំនួន ៧០នាក់។

ការពិភាក្សា និងពិនិត្យលើផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ.

នៅរសៀលថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម យក់ ម៉ិនណា រដ្ឋលេខាធិការប្រចាំការ និងជាប្រធានអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ.** បានដឹកនាំកិច្ចប្រជុំពិភាក្សា និងពិនិត្យលើផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ. ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ តំណាង ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងទីប្រឹក្សា **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ព្រមទាំង ឯកឧត្តម លោកជំទាវ ប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍ នៃក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ. សរុបប្រមាណ ៥០ រូប។

គោលបំណងនៃកិច្ចប្រជុំនាពេលនេះគឺពិភាក្សាពិគ្រោះយោបល់ និងប្រមូលធាតុចូលនិងមតិយោបល់ពីអង្គប្រជុំតំណាងក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងទីប្រឹក្សាសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ដើម្បីជាមូលដ្ឋានក្នុងការកែសម្រួលផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ.។

អង្គប្រជុំបានប្រព្រឹត្តទៅតាមរយៈការរាយការណ៍អំពីវឌ្ឍនភាពនៃការរៀបចំផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសទាំង៣ នៃអនុគណៈកម្មាធិការប្រតិបត្តិ គ.វ.រ. ដោយ **ឯកឧត្តម ឈុន សុជាតិ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ក.ស.** និងការធ្វើបទបង្ហាញអំពីផែនការសកម្មភាពដោយ ប្រធានក្រុមការងារបច្ចេកទេសនីមួយៗ។

ឯកឧត្តម ប្រធានអង្គប្រជុំ ក៏បានណែនាំ និងធ្វើការតម្រង់ទិសបន្ថែមទៀតដល់ក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវគិតគូរទៅលើចំណុចសំខាន់ៗចំនួន ៤ ដើម្បីទទួលបានភាពជោគជ័យក្នុងការអនុវត្តផែនការសកម្មភាពរួមមាន៖

(១)ក្របខណ្ឌពេលវេលា

(២)យន្តការស្ថាប័នសម្រាប់ការអនុវត្ត

(៣)ប្រភពថវិកាគាំទ្រការអនុវត្ត

(៤)ការរៀបចំស្តង់ដារក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ការពិនិត្យ និងពិភាក្សា លើឯកសារនិយាមនីតិវិធីប្រតិបត្តិ ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ និងឯកសារទស្សនទាន ស្តីពីការជ្រើសរើស និងការប្រើប្រាស់មន្ត្រីបច្ចេកទេសសុខាភិបាល

នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម យក់ ម៉ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សា លើឯកសារនិយាមនីតិវិធីប្រតិបត្តិ ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ និងឯកសារទស្សនទាន ស្តីពីការជ្រើសរើស និងការប្រើប្រាស់មន្ត្រីបច្ចេកទេសសុខាភិបាល នៅសាលាភូមិន្ទរដ្ឋបាល ដោយមានការចូលរួមតំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងជំនួយការសម្តេចធិបតី តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងអប់រំ យុវជន និងកីឡា តំណាងក្រសួងសុខាភិបាល តំណាងក្រុមអ្នកច្បាប់ ព្រមទាំងថ្នាក់ដឹកនាំ និងអង្គភាពជំនាញ របស់ក្រសួងមុខងារសាធារណៈ មានចំនួនសរុបប្រមាណ ៧០នាក់។

បន្ទាប់ពីបានស្តាប់របាយការណ៍សង្ខេបខ្លឹមសារគោលនៃសេចក្តីព្រាងនិយាមនីតិវិធីប្រតិបត្តិ ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ដោយ **ឯកឧត្តម គង់ សុនី** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ រួចមក អង្គប្រជុំបានពិភាក្សាដើម្បីប្រមូលផ្តល់ធាតុចូលបន្ថែម ក្នុងកែសម្រួលនូវចំណុចខ្វះខាតលើការរៀបចំសេចក្តីព្រាងនិយាមនីតិវិធីប្រតិបត្តិនេះ។

ជាលទ្ធផលនៃកិច្ចប្រជុំពិភាក្សា អង្គប្រជុំបានផ្តល់មតិយោបល់ដែលជាធាតុចូលយ៉ាងផុលផុស និងឯកភាពទៅលើចំណុចសំខាន់ៗ ដើម្បីឱ្យនិយាមនេះ មានលក្ខណៈសង្គតិភាព និងជាគោលការណ៍រួម សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ប្រកបដោយតម្លាភាព យុត្តិធម៌ បរិយាបន្ន ស្របតាមប្រសាសន៍របស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ថា ***"ការប្រលងជ្រើសរើសមន្ត្រីថ្មី គឺដាច់ខាតត្រូវតែមានសុក្រឹត្យភាព ឱ្យអ្នកចេះ គឺជាប់"*** រួមមាន៖ ១)កែសម្រួលអក្ខរាវិរុទ្ធ ២)កែសម្រួលពាក្យពេចន៍ ឃ្លា និងខ្លឹមសារមួយចំនួន ៣)បន្ថែមនិងលុបចំណុចមួយចំនួន ៤)កំណត់ឱ្យក្រុមការងារពិចារណាបន្ថែមសទ្ទានុក្រមពាក្យគន្លឹះមួយចំនួនដូចជា៖ ភាសាខ្មែរ និងភាសាអង់គ្លេស។

ការពិនិត្យ និងពិភាក្សាលើ ឯកសារនិយាមនីតិវិធីប្រតិបត្តិ ស្តីពីការប្រឡងប្រជែងជ្រើសរើស មន្ត្រីរាជការស៊ីវិល នៅសាលាភូមិន្ទរដ្ឋបាល

នារសៀលថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការប្រឡងប្រជែង បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើ ឯកសារនិយាមនីតិវិធីប្រតិបត្តិ ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល នៅសាលាភូមិន្ទរដ្ឋបាល ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសជាច្រើនរូបរបស់ក្រសួងមុខងារសាធារណៈ។

កិច្ចប្រជុំនោះ **ឯកឧត្តម គង់ សុភី** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ បានធ្វើបទបង្ហាញនៃសេចក្តីព្រាងនិយាមនីតិប្រតិបត្តិជូនអង្គប្រជុំ។ អង្គប្រជុំក៏បានពិភាក្សា និងផ្តល់ជាធាតុចូលជាច្រើន ដើម្បីធ្វើយ៉ាងណារៀបចំនិយាមនេះឱ្យសម្រេចបានក្នុងពេលឆាប់ៗ ឆ្ពោះទៅការពិភាក្សាជាបន្ត ជាមួយក្រុមការងារអន្តរក្រសួងដែលជាភាគីពាក់ព័ន្ធ ជាពិសេស ក្រសួង ស្ថាប័ន ដែលមានតម្រូវការជ្រើសមន្ត្រីរាជការ។

ក្នុងកិច្ចប្រជុំនោះដែរ **ឯកឧត្តមរដ្ឋមន្ត្រី** បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការចូលរួមសហការតាក់តែង និងបានលើកឡើងថា ក្រសួងមុខងារសាធារណៈ មានបទពិសោធន៍គ្រប់គ្រាន់រួចជាស្រេចមកហើយ ក្នុងការរៀបចំនិយាមនេះ ដោយឡែកពេលនេះ ក្រសួងបានយកបទពិសោធន៍ដែលបានធ្វើនាពេលកន្លងមក ដាក់បញ្ចូលទៅជា ឯកសារនិយាមនិតិវិធីប្រតិបត្តិ ដើម្បីឱ្យមានស្តង់ដាររួមនៅក្នុងការអនុវត្តការងារស្របតាមគោលដៅកែទម្រង់រដ្ឋបាលសាធារណៈ នៃយុទ្ធសាស្រ្តបញ្ចកោណ តំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

ការពិនិត្យពិភាក្សាការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការពិនិត្យស្ថានភាពបុគ្គលិកសុខាភិបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ បានដឹកនាំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង លើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្រសួងមុខងារសាធារណៈ ដោយពិនិត្យពិភាក្សាការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការពិនិត្យស្ថានភាពបុគ្គលិកសុខាភិបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងសុខាភិបាល តំណាងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសរបស់ក្រសួងមុខងារសាធារណៈជាច្រើនរូប។

បន្ទាប់ពីបានស្តាប់របាយការណ៍សង្ខេបនៃកិច្ចប្រជុំកាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ និងវឌ្ឍនភាពការងារព្រមទាំងបញ្ហាប្រឈម ដោយ **ឯកឧត្តម ថោ សេដ្ឋាណា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ រួចមក អង្គប្រជុំបានពិនិត្យ និងពិភាក្សាទៅលើការងារសម្រាប់ថ្នាក់ក្រោមជាតិ ដើម្បីរៀបចំយន្តការការងារបន្ត រួមមាន៖ ១) ធ្វើបច្ចុប្បន្នភាពអង្គភាព និងមន្ត្រីកំពុងបម្រើការងារជាក់ស្តែង ២) រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ប្រមូលទិន្នន័យ ៣) យន្តការរបស់ស្ថាប័ន ៤) ពេលវេលាអនុវត្តន៍ និង ៥) ប្រភពថវិកាគាំទ្រ។

ក្រោយពីតំណាងក្រសួង ស្ថាប័ន ពាក់ព័ន្ធបានពិភាក្សាការងារដែលបានកំណត់ និងបញ្ហាដែលបានជួបប្រទះ ព្រមទាំងមតិយោបល់ជាធាតុចូលយ៉ាងច្រើនរួចមក អង្គប្រជុំបានគាំទ្រយ៉ាងពេញទំហឹងចំពោះយន្តការប្រមូលទិន្នន័យរបស់ក្រសួងមុខងារសាធារណៈ ដែលកំពុងរៀបចំនៅពេលនេះ និងសម្រេចឯកភាពលើការងារប្រមូលទិន្នន័យជាក់ស្តែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន៖

១) កម្មវិធីបច្ចុប្បន្នភាពទិន្នន័យនៅទីតាំងផ្តល់សេវាសុខាភិបាលដល់ប្រជាពលរដ្ឋនិងទីតាំងផ្តល់សេវាអប់រំ

២) ក្រុមការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្រសួងមុខងារសាធារណៈ ត្រូវរៀបចំសេចក្តីព្រាងឯកសារទស្សនទានសម្រាប់ការធ្វើបច្ចុប្បន្នភាពទិន្នន័យ ទាំងផ្នែកសុខាភិបាល ទាំងផ្នែកអប់រំ ឱ្យបានរួចរាល់នៅពីរសប្តាហ៍ទៀត

៣) ក្រុមការងារបច្ចេកទេសឌីជីថល ក្រសួងមុខងារសាធារណៈ ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា សហការគ្នា ដើម្បីពិនិត្យលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យារួមគ្នាក្នុងទទួលខុសត្រូវការរៀបចំបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ។

ការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងក្របខណ្ឌអគ្គលេខាធិការដ្ឋាន គ.ក.ស.

ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ក.ស. បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន ចំណុះអគ្គលេខាធិការដ្ឋាន គ.ក.ស. រួមជាមួយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ សរុបប្រមាណ ២៥រូប។

កិច្ចប្រជុំបានប្រព្រឹត្តទៅនៅសាលប្រជុំ នៃអគារគណៈកម្មាធិការកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងបរិវេណសាលាភូមិន្ទរដ្ឋបាល ដោយបានពិភាក្សាពិគ្រោះយោបល់និងផ្តល់ជាធាតុចូលសម្រាប់ជាមូលដ្ឋានក្នុងការកែសម្រួលកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ស្របតាមវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

ក្នុងកិច្ចប្រជុំ ឯកឧត្តមប្រធានអង្គប្រជុំបានណែនាំដល់ក្រុមការងារទទួលបន្ទុករៀបចំឯកសារកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ធ្វើការកែសម្រួលឯកសារដោយយោងតាមស្មារតីនៃអង្គប្រជុំ និងបានស្នើសុំដល់អង្គប្រជុំធ្វើការពិនិត្យនិងផ្តល់ជាធាតុចូលបន្ថែមទៀតក្រោយបញ្ចប់កិច្ចប្រជុំនេះ ដើម្បីត្រៀមដាក់ឆ្លងក្នុងកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំនាពេលខាងមុខ។

ការពិនិត្យសកម្មភាពតាក់តែងវិញ្ញាសា របស់គណៈមេប្រយោគ នៃគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើស គ្រូបង្រៀនឯកទេសអប់រំកាយនិងកីឡា

ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៤ នាមណ្ឌលប្រឡងវិញ្ញាសាសរសេរ ស្ថិតក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច **ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការប្រឡងប្រជែង** បានចុះពិនិត្យសកម្មភាពតាក់តែងវិញ្ញាសា របស់គណៈមេប្រយោគ នៃគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើស គ្រូបង្រៀនឯកទេសអប់រំកាយនិងកីឡា ។

ខណៈនេះ គណៈកម្មការមេប្រយោគ កំពុងដំណើរការរៀបចំ និងតាក់តែងវិញ្ញាសាសម្រាប់បេក្ខជនប្រឡងប្រជែងយ៉ាងសស្រាក់សស្រាំ និងដោយសម្ងាត់ពីសាស្ត្រាចារ្យជំនាញ ក្រោមការសង្កេតការណ៍ពីតំណាងអង្គភាពប្រឆាំងអំពើពុករលួយ សហភាពសហព័ន្ធយុវជនកម្ពុជា តំណាងសាកលវិទ្យាល័យនានា និងសាធារណជនដែលបានចុះឈ្មោះ សម្រាប់ការប្រឡងនារសៀលនេះក្នុងថ្ងៃតែមួយ។

សូមបញ្ជាក់ថា វិញ្ញាសាកំពុងតាក់តែងមានចំនួន៣ រួមមាន៖ ១.វិញ្ញាសាវប្បធម៌ទូទៅ ២.វិញ្ញាសាជីវវិទ្យា និង ៣.វិញ្ញាសាភាសាអង់គ្លេស។

នីតិវិធីនៃការពិនិត្យលើលទ្ធផលនៃការវាយតម្លៃនៅទីតាំងជាក់ស្តែង បេក្ខភាពសម្រាំង អនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខភាពគំរូ របស់គណៈកម្មការបច្ចេកទេសអន្តរក្រសួងនៃ គ.វ.ជ.

ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងមុខងារសាធារណៈ **ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ (គ.វ.ជ.)** បានដឹកនាំកិច្ចប្រជុំគណៈកម្មការបន្តនីតិវិធីពិនិត្យលើលទ្ធផលនៃការវាយតម្លៃនៅទីតាំងជាក់ស្តែងបេក្ខភាពសម្រាំង អនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខភាពគំរូ របស់គណៈកម្មការបច្ចេកទេសអន្តរក្រសួងនៃ គ.វ.ជ. ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងក្រសួងអប់រំ យុវជន និងកីឡា តំណាងក្រសួងសុខាភិបាល ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញក្រសួងមុខងារសាធារណៈ និងស្ថាប័នអង្គភាពពាក់ព័ន្ធជាច្រើនរូបទៀត។

កិច្ចប្រជុំនេះធ្វើឡើង បន្ទាប់ពីគណៈកម្មការបច្ចេកទេសអន្តរក្រសួងនៃ គ.វ.ជ. បានចុះពិនិត្យនិងវាយតម្លៃ ទីតាំងផ្ទាល់ជាក់ស្តែង សម្រាប់បេក្ខភាពសម្រាំងអនុវិទ្យាល័យ និងបឋមសិក្សា ព្រមទាំងមណ្ឌលសុខភាពគំរូ ក្នុងគោលបំណងជ្រើសរើសបេក្ខភាពគំរូឆ្នើមប្រចាំឆ្នាំ ដើម្បីឈានទៅដល់ការប្រកាសជ័យលាភីចុងក្រោយ។

ថ្លែងក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីគុណតម្លៃនៃដំណើរការការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ហើយក៏បានលើកបន្ថែមផងទៀតថា កិច្ចការនេះគឺជាការបំផុសស្មារតីប្រកួតប្រជែងបន្ថែមទៀត ជាពិសេសនៅក្នុងកិច្ចការកែទម្រង់រដ្ឋបាលសាធារណៈ និងធ្វើទំនើបកម្មស្ថាប័ន ដើម្បីផ្តល់សេវាសាធារណៈជូនទៅដល់ប្រជាពលរដ្ឋកាន់តែមានភាពល្អប្រសើរ។

ការពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីគោលការណ៍នៃការបង្កើតអង្គភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង-ស្ថាប័ន

ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងមុខងារសាធារណៈ **ឯកឧត្តម គង់ សុភី រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ** បានដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីគោលការណ៍នៃការបង្កើតអង្គភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង-ស្ថាប័ន ដោយមានការចូលរួមពីតំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងឱ្យអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និងថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃក្រសួងមុខងារសាធារណៈជាច្រើនរូប។

បន្ទាប់ពីការពិភាក្សា **ឯកឧត្តម គង់ សុភី** បានស្នើអង្គប្រជុំអោយមានការឯកភាពជាគោលការណ៍លើសំណើចំនួន២ ដូចខាងក្រោម និងគោរពរាយការណ៍ជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីពិនិត្យនិងសម្រេចៈ

១) កែប្រែសេចក្តីព្រាងអនុក្រឹត្យនេះ ទៅជាសារាចរណែនាំរបស់រាជរដ្ឋាភិបាល

២) បង្កើតក្រុមការងារចំពោះកិច្ចក្នុងក្របខណ្ឌគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ដើម្បីចុះសិក្សាវាយតម្លៃអំពីតម្រូវការ និងទំហំការងារជាក់ស្តែង។

សូមជម្រាបថា ការបង្កើតអង្គភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង-ស្ថាប័ន ក្នុងគោលបំណងដើម្បីជំរុញការកសាងរដ្ឋាភិបាលឌីជីថល និងការផ្តល់សេវាសាធារណៈឌីជីថលក្នុងការពង្រឹងប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភា។

ការពិនិត្យ និងពិភាក្សាការងាររបស់ក្រុមការងារកែលម្អប្រព័ន្ធលើកទឹកចិត្ត ផ្អែកលើសមិទ្ធកម្ម នៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.ក.រ.

នាព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម យក់ ម៉ុនណា** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ. បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាការងាររបស់ក្រុមការងារកែលម្អប្រព័ន្ធលើកទឹកចិត្ត ផ្អែកលើសមិទ្ធកម្ម នៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ. ដែលការងារនេះជាផ្នែកមួយវិធានគន្លឹះក្នុងការងារកំណែទម្រង់ របស់ក្រសួងមុខងារសាធារណៈ។

កិច្ចប្រជុំនេះប្រព្រឹត្តទៅនៅសាលាភូមិន្ទរដ្ឋបាល ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការរង នៃ អ.គ.ក.ស. លោក លោកស្រី ជាប្រធាន ឬតំណាងក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី នៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ តំណាងក្រុមការងារបច្ចេកទេសលើប្រសិទ្ធភាពការងារ នៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ. និងសមាជិកនៃក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម នៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ.។

កិច្ចប្រជុំបានចូលរួមមតិយោបល់យ៉ាងច្រើនដែលជាធាតុចូលឆ្ពោះទៅកាន់ការរៀបចំឯកសារគោលផ្សេងៗទៀត ដើម្បីយកទៅពិភាក្សាគ្នាក្នុងកិច្ចប្រជុំបន្តនៅពេលក្រោយ។

ការពិនិត្យ និងពិភាក្សាលើឯកសារទស្សនទាន ស្តីពីការជ្រើសរើស និងការប្រើប្រាស់មន្ត្រីបច្ចេកទេសសុខាភិបាល

កាលពីរសៀលថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ នេះ **ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការ និងជាប្រធានអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.រ.រ.** បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើឯកសារទស្សនទាន ស្តីពីការជ្រើសរើស និងការប្រើប្រាស់មន្ត្រីបច្ចេកទេសសុខាភិបាល នៅសាលាភូមិន្ទរដ្ឋបាល ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការរង នៃ អ.គ.ក.ស. លោក លោកស្រី ជាប្រធាន ឬតំណាងក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី ក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម និងមន្ត្រីជំនាញនៃក្រសួងមុខងារសាធារណៈ សរុបចំនួនប្រមាណ ៣០នាក់។

បន្ទាប់ពីបានពិភាក្សា និងពិគ្រោះយោបល់ប្រកបដោយភាពល្អិតល្អន់រួចមក អង្គប្រជុំ បានសម្រេចលើការងារមួយចំនួនរួមមាន៖

១-រៀបចំកែសម្រួលឯកសារទស្សនទានអំពីការជ្រើសរើស និងការប្រើប្រាស់មន្ត្រីបច្ចេកទេសសុខាភិបាល ដោយឆ្លុះបញ្ចាំងបន្ថែមពីអត្ថប្រយោជន៍ គុណសម្បត្តិ គុណវិបត្តិ នៃប្រព័ន្ធជ្រើសរើសមន្ត្រី

២-រៀបចំសេចក្តីព្រាងអនុក្រឹត្យពាក់ព័ន្ធលើការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីបច្ចេកទេស ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពពីអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។

៣-រៀបចំនិយាមប្រតិបត្តិក្នុងការជ្រើសរើសនិងគ្រប់គ្រងមន្ត្រីបច្ចេកទេស ដើម្បីជាឧបករណ៍គតិយុត្តមូលដ្ឋានសម្រាប់ដាក់ឱ្យអនុវត្តក្នុងការរៀបចំការជ្រើសរើសមន្ត្រីបច្ចេកទេស។

ការពិនិត្យនិងពិភាក្សាលើផែនការសកម្មភាពរបស់អនុគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈទាំង៤ នៃ គ.ក.ស. សម្រាប់អនុវត្តក្នុងឆ្នាំ២០២៤

ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការ និងជាអនុប្រធានប្រចាំការគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ** បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើផែនការសកម្មភាពរបស់អនុគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈទាំង៤ នៃ គ.ក.ស. សម្រាប់អនុវត្តក្នុងឆ្នាំ២០២៤ នៅសាលាភូមិន្ទរដ្ឋបាល ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជាប្រធាន អនុប្រធាន និងលោក លោកស្រី ជាសមាជិកអនុគណៈកម្មាធិការ មានចំនួនសរុប ៤០នាក់។

បន្ទាប់ពីបានស្តាប់របាយការណ៍របស់អនុគណៈកម្មាធិការនីមួយៗ ឯកឧត្តមប្រធានបានផ្តល់ប្រសាសន៍ណែនាំតម្រង់ទិស ជូនក្រុមការងារ ឱ្យពិនិត្យ និងសិក្សាលើការបន្ស៊ីសកម្មភាពការងាររបស់អនុគណៈកម្មាធិការនីមួយៗឱ្យមានសង្គតភាព ហើយគាំទ្រគ្នាទៅវិញទៅមក ជៀសវាងមានការជាន់តួនាទីភារកិច្ចគ្នា។ ទន្ទឹមនឹងនោះ ឯកឧត្តមប្រធានអង្គប្រជុំក៏បានបន្ថែមថារាល់ការរៀបចំផែនការការងារ គប្បីគិតគូរពីទិដ្ឋភាពរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។

ឯកឧត្តមប្រធានអង្គប្រជុំ បានកំណត់កាលបរិច្ឆេទការរៀបចំផែនការឡើងវិញរបស់អនុគណៈកម្មាធិការនីមួយៗ ដោយភ្ជាប់ជាមួយផែនការថវិកាមកជាមួយនៅកិច្ចប្រជុំបន្ទាប់នាសប្តាហ៍ក្រោយ។

កិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សារកធាតុចូលអំពីសេចក្តីព្រាង និយាមនីតិវិធីប្រតិបត្តិ(SOP) សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល

នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ(គ.វ.រ.) បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ដែលដឹកនាំដោយ **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាអនុប្រធានប្រចាំការ នៃ គ.វ.រ.។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី ប្រតិភូអមរាជរដ្ឋាភិបាល រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ថ្នាក់ដឹកនាំក្រសួង-ស្ថាប័នទាំងអស់ ដែលជាសមាជិក នៃ គ.វ.រ. និងក្រុមបច្ចេកទេស នៃ គ.វ.រ. និងថ្នាក់ដឹកនាំពាក់ព័ន្ធរបស់ក្រសួងមុខងារសាធារណៈ ព្រមទាំងអភិបាល អភិបាលរង នៃគណអភិបាលរាជធានី-ខេត្ត សរុបចំនួនប្រមាណជិត ២០០នាក់។

ឯកឧត្តមរដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានអនុញ្ញាតឱ្យ **ឯកឧត្តម គង់ សុភី** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី នៃអនុគណៈកម្មាធិការប្រតិបត្តិ នៃ គ.វ.រ. ធ្វើបទបង្ហាញ និងរបាយការណ៍វឌ្ឍនភាពនៃការរៀបចំឯកសារនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ជូនអង្គប្រជុំបានស្តាប់ និងពិគ្រោះយោបល់ បញ្ចូលធាតុចូល ស្របតាមតម្រូវការរួមរបស់ក្រសួង-ស្ថាប័ននីមួយៗ ក្នុងការឱ្យនិយាមមួយនេះ ក្លាយជាឯកសារគោលរួមមួយសម្រាប់គ្រប់ក្រសួង-ស្ថាប័ន យកទៅអនុវត្តន៍។

ចុងបញ្ចប់ **ឯកឧត្តមរដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់ក្រុមការងារ និងការចូលរួមរបស់ឯកឧត្តម លោកជំទាវនៃអង្គប្រជុំទាំងអស់ បានផ្តល់មតិយោបល់យ៉ាងច្រើន ដែលនេះជាអ្វីដែលយើងចង់បានដើម្បីរៀនសូត្រពីកិច្ចពិភាក្សាជាបន្តបន្ទាប់ ដែលចេញពីបទពិសោធន៍របស់យើងទទួលបានមកពីការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ទាំងពីរលើកកន្លងមក ហើយសម្រាប់ថ្ងៃនេះជាការប្រមូលធាតុចូលពីក្រសួង-ស្ថាប័នដោយផ្ទាល់។

ដំណាក់កាលពិនិត្យវាយតម្លៃចុងក្រោយ របស់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ (គ.វ.ជ.) ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៣

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈ ថ្នាក់ជាតិ (គ.វ.ជ.) បានដំណើរការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ (អ.ផ.ស.) ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៣ ដំណាក់កាលពិនិត្យវាយតម្លៃចុងក្រោយ ចាប់ផ្តើមនៅព្រឹកថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធាន គ.វ.ជ.។ អង្គភាពលេចធ្លោជាងគេចំនួន១៥ អង្គភាព ទាំងវិស័យអប់រំ និងវិស័យសុខាភិបាល បានធ្វើបទបង្ហាញនៃភាពជាអង្គភាពផ្តល់សេវាសាធារណៈគំរូ ជូនគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ (គ.វ.ជ.) ដែលមានសមាសភាពមកពីបណ្តាអន្តរក្រសួង ស្ថាប័នចម្រុះ។

ការវាយតម្លៃ និងទទួលស្គាល់នូវអង្គភាពផ្តល់សេវាសាធារណៈគំរូនេះ ប្រព្រឹត្តទៅរយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសាលាភូមិន្ទរដ្ឋបាល។

ជំនួបពិភាក្សា របស់ក្រសួងមុខងារសាធារណៈជាមួយក្រុមការងារធនាគារពិភពលោក ប្រចាំនៅកម្ពុជា ជុំវិញការងារបណ្តុះបណ្តាលធនធានមនុស្ស

នារសៀលថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ បានដឹកនាំក្រុមការងារក្រសួងមុខងារសាធារណៈ ជួបពិភាក្សាការងារជាមួយក្រុមការងារធនាគារពិភពលោកប្រចាំនៅកម្ពុជា ដែលដឹកនាំដោយ **លោក សូ សុខប៊ុនធឿន** អ្នកជំនាញជាន់ខ្ពស់ផ្នែកសាធារណៈ ជុំវិញការងារបណ្តុះបណ្តាលធនធានមនុស្ស នៅសាលាភូមិន្ទរដ្ឋបាល។

កិច្ចប្រជុំនេះបានពិភាក្សាដោយផ្តោតលើប្រធានបទមួយចំនួន រួមមាន៖ (១) ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ (២) វឌ្ឍនភាពនៃការធ្វើបច្ចុប្បន្នភាពកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដោយរួមបញ្ចូលទាំងការគិតគូរលើការកែទម្រង់រដ្ឋបាលសាធារណៈ លើវិស័យអាទិភាពជាពិសេសវិស័យអប់រំ (៣) កម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងនវានុវត្តន៍ និង (៤) វឌ្ឍនភាពនៃការងាររៀបចំប្រព័ន្ធផ្ទុកទិន្នន័យមន្ត្រីរាជការ (HRMIS prototype implementation) និងការងារបន្ត។

សូមបញ្ជាក់ថា កន្លងមក ក្រុមការងារធនាគារពិភពលោកប្រចាំនៅកម្ពុជា តែងតែបានផ្តល់ការគាំទ្រជាបច្ចេកទេសដល់ក្រសួងមុខងារសាធារណៈ ទាំងលើការងារដែលបានជួបពិភាក្សានាពេលនេះ និងពិនិត្យលទ្ធភាពដើម្បីផ្តល់ការគាំទ្របន្ថែមនាថ្ងៃអនាគត និងការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្នុងការបំពេញការងារឱ្យល្អថែមមួយកម្រិតទៀតផងដែរ។

ក្រសួងមុខងារសាធារណៈ ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សារៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ៥ ក្រសួងស្ថាប័នទៀត

ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការប្រឡងប្រជែង បានដឹកនាំកិច្ចប្រជុំពិភាក្សាលើការរៀបចំដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័នចំនួន៥ រួមមាន ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គភាពប្រឆាំងអំពើពុករលួយ នៅទីស្តីការក្រសួងមុខងារសាធារណៈ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រី** និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំតំណាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ រួមទាំងមន្ត្រីបច្ចេកទេសជាច្រើនរូបរបស់ក្រសួងមុខងារសាធារណៈ និងក្រសួងពាក់ព័ន្ធ សរុបចំនួនប្រមាណ ១២០នាក់។

កិច្ចប្រជុំនេះបានដំណើរការទៅដោយការធ្វើបាយការណ៍ និងពិភាក្សាដើម្បីកំណត់ការបរិច្ឆេទសម្រាប់ការប្រឡងប្រជែង រួមទាំងនីតិវិធីនានាអនុលោមគោលការណ៍ដែលមានចែង ហើយដើរស្របតាមនិយាមនីតិវិធីប្រតិបត្តិ ក្នុងការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីរាជការស៊ីវិល ដែលជាទស្សនវិស័យដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**។

សូមជម្រាបថា រាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភាបានយកយន្តការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីរាជការ ជាវិធានការគន្លឹះមួយ ក្នុងគោលដៅកែទម្រង់រដ្ឋបាលសាធារណៈ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងមុខងារសាធារណៈ មានឆន្ទៈខ្ពស់ក្នុងការផ្តល់ឱកាសស្មើៗគ្នា ក្នុងការប្រឡងប្រជែងជាមន្ត្រីរាជការស៊ីវិល ជាបន្តបន្ទាប់។ សូមរង់ចាំតាមដាន ការផ្សព្វផ្សាយពីឱកាសទាំងអស់នោះ នៅតាមរយៈគេហទំព័រផ្លូវការរបស់ក្រសួងមុខងារសាធារណៈ។

ក្រសួងមុខងារសាធារណៈ ជួបជាមួយក្រុមការងារអន្តរក្រសួង ដើម្បីពិភាក្សាលើបច្ចុប្បន្នកម្មនៃប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ និងជាអនុប្រធានប្រធានប្រចាំការគណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួងមុខងារសាធារណៈ បានដឹកនាំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង លើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្រសួងមុខងារសាធារណៈ ដោយពិនិត្យពិភាក្សាលើការដាក់ឱ្យអនុវត្តការធ្វើបច្ចុប្បន្នភាពលើប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ សម្រាប់រៀបចំទិន្នន័យគ្រូបង្រៀន គ្រឹះស្ថានបឋមសិក្សាសាធារណៈ មត្តេយ្យសិក្សាសាធារណៈ និងមត្តេយ្យសិក្សាសហគមន៍ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងទិន្នន័យមន្ត្រីបច្ចេកទេសផ្នែកសុខាភិបាល រដ្ឋបាលនៅថ្នាក់ក្រោមជាតិមណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងសុខាភិបាល តំណាងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសរបស់ក្រសួងមុខងារសាធារណៈជាច្រើនរូប។

កិច្ចចាប់ផ្តើម **ឯកឧត្តមប្រធានអង្គប្រជុំ** បានធ្វើមតិស្វាគមន៍ និងបង្ហាញពីគោលបំណងក្នុងការបង្កើតប្រព័ន្ធប្រមូលទិន្នន័យ ដើម្បីធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការថ្នាក់ក្រោមជាតិដែលកំពុងបម្រើការងារជាក់ស្តែង ដោយមិនប៉ះពាល់ទៅលើប្រព័ន្ធទិន្នន័យរបស់ក្រសួង-ស្ថាប័នសាមីទេ។ **ឯកឧត្តមប្រធាន** បានអនុញ្ញាតឱ្យ **ឯកឧត្តម ឡុង សារឿន** អគ្គនាយកនៃអគ្គនាយកដ្ឋានប្រព័ន្ធគ្រប់គ្រងមន្ត្រីតាមប្រព័ន្ធឌីជីថលនៃក្រសួងមុខងារសាធារណៈ ធ្វើបទបង្ហាញសង្ខេបពីវឌ្ឍនភាពការងារនៃការរៀបចំប្រព័ន្ធ និងលទ្ធផលដែលរំពឹងទុក ព្រមទាំងដាក់ជូនអង្គប្រជុំពិភាក្សា ដោយលើកនូវមតិយោបល់ និងបញ្ហាផ្សេងៗទៅតាមតំណាងក្រសួង-ស្ថាប័ន បានជួបនៅពេលបំពេញការងារជាក់ស្តែង។

ក្រោយពីតំណាងក្រសួង-ស្ថាប័ន ពាក់ព័ន្ធបានពិភាក្សាការងារដែលបានកំណត់ និងបញ្ហាដែលបានជួបប្រទះ ព្រមទាំងមតិយោបល់ជាធាតុចូលយ៉ាងច្រើនរួចមក អង្គប្រជុំបានគាំទ្រយ៉ាងពេញទំហឹងចំពោះយន្តការប្រមូលទិន្នន័យរបស់ក្រសួងមុខងារសាធារណៈ ដែលកំពុងរៀបចំនៅពេលនេះ និងសម្រេចឯកភាពលើការងារប្រមូលទិន្នន័យជាក់ស្តែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយយល់ព្រមឱ្យក្រុមការងារបច្ចេកទេសឌីជីថលក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា សហការពិនិត្យលទ្ធភាពផ្តល់ទិន្នន័យមន្ត្រីរាជការតាមការចង់បានរបស់ក្រសួងមុខងារសាធារណៈ ក្នុងការរៀបចំបញ្ចូលទិន្នន័យមន្ត្រីរាជការថ្នាក់ក្រោមជាតិទៅក្នុងប្រព័ន្ធ។

ប្រតិភូក្រសួងមុខងារសាធារណៈ
ចូលរួមកិច្ចប្រជុំក្នុងក្របខណ្ឌការដ្ឋានកែទម្រង់ ៣ បូក ១

នាព្រឹកថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានដឹកនាំក្រុមការងារបច្ចេកទេស តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ចូលរួមកិច្ចប្រជុំក្នុងក្របខណ្ឌការដ្ឋានកែទម្រង់ ៣ បូក ១ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កិច្ចប្រជុំបានពិភាក្សាទៅលើការងារកែទម្រង់រដ្ឋបាលសាធារណៈ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងារកែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ឆ្នាំ២០២៣ និងពិនិត្យលើសំណើផែនការសកម្មភាពសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ ឆ្នាំ២០២៤ រួមទាំងការត្រៀមរៀបចំទស្សនកិច្ចសិក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំវិបស្សនាកែទម្រង់ ៣ បូក ១ នាពេលខាងមុខផងដែរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហ៊ុន ម៉ានី៖ ការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ជាផ្នែកមួយបង្ហាញពីឧត្តមភាពនៃមន្ត្រីរាជការស៊ីវិលគ្រប់ជាន់ថ្នាក់

ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ បានលើកឡើងថា ការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ជាផ្នែកមួយនៃការបង្ហាញពីឧត្តមភាពនៃមន្ត្រីរាជការស៊ីវិលគ្រប់ជាន់ថ្នាក់ នៃការខិតខំប្រឹងប្រែងរបស់មន្ត្រីនីមួយៗ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងដូចនេះ នៅក្នុងពិធីបិទសិក្ខាសាលាចែករំលែកបទពិសោធន៍នៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ របស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឆ្នាំ២០២៣ នៅសាលមហោស្រពនៃមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ នារសៀលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤។

ជុំវិញការលើកឡើងនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសកម្មភាពនានានៃការអនុវត្តការងាររបស់មន្ត្រីរាជការស៊ីវិលគ្រប់ជាន់ថ្នាក់ទាំងអស់ ក្នុងគោលដៅបម្រើជាតិ និងប្រជាជន និងដើម្បីបង្ហាញពីឧត្តមភាពរបស់មន្ត្រីរាជការផង ព្រមទាំងអាចបង្កើននូវភាពជាគំរូ ដល់មន្ត្រីដទៃផ្សេងទៀតផងដែរ។

សូមបញ្ជាក់ថា ពិធីប្រកាសជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ឆ្នាំ២០២៣ នឹងប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីប្រកាសជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងសុខាភិបាល ឆ្នាំ២០២៣ និងប្រកាសដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ២០២៤

នាព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលឆ្នាំ២០២៣ និងប្រកាសដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ២០២៤ នៅសាលមហោស្រពនៃមជ្ឈមណ្ឌលសន្និបាត និងពិព័ណ៌កោះពេជ្រ។

ក្នុងរបាយការណ៍បូកសរុប ស្តីពីការអនុវត្តការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដោយ **ឯកឧត្តម ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

ជាលទ្ធផលនៃការវាយតម្លៃរបស់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្នុងឆ្នាំ២០២៣ អង្គភាពដែលទទួលជ័យលាភីជាអង្គភាពគំរូចំណាត់ថ្នាក់លេខ១ ចំនួន៣ សម្រាប់វិស័យអប់រំ រួមមាន៖ សាលាអនុវិទ្យាល័យភ្នំយ៉ាត ខេត្តប៉ៃលិន សាលាបឋមសិក្សាស្វាយជ្រំ ខេត្តស្វាយរៀង និង

សាលាបឋមសិក្សាសម្តេចជាស៊ីម ខេត្តបាត់ដំបង និងអង្គភាពដែលទទួលជ័យលាភីជាអង្គភាពគំរូចំណាត់ថ្នាក់លេខ១ សម្រាប់វិស័យសុខាភិបាលគឺ មណ្ឌលសុខភាពសំរោង ខេត្តពោធិ៍សាត់។

សូមជម្រាបថា ក្រោយពីជំងឺកូវីដ-១៩ ត្រូវបានគ្រប់គ្រងទាំងស្រុង ក្រសួងមុខងារសាធារណៈ និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ បានបន្តនិរន្តរភាពការងារ និងជំរុញការអនុវត្តការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល (ឆ្នាំ២០២២ និង២០២៣) ដែលមានបេក្ខភាពសរុប ក្នុងវិស័យអប់រំកម្រិតអនុវិទ្យាល័យចំនួន៤២ មកពី២២ រាជធានីខេត្ត កម្រិតសាលាបឋមសិក្សាចំនួន៤៦ មកពី២៤ រាជធានី ខេត្ត និងក្នុងវិស័យសុខាភិបាល មានបេក្ខភាពមណ្ឌលសុខភាពចំនួន៤៣ មកពី២២ រាជធានីខេត្ត។

គណៈកម្មការរៀបចំការប្រឡងប្រជែង ប្រជុំពិនិត្យពិភាក្សាលើការរៀបចំដំណើរការ ប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការចំនួន ៣ ក្រសួង-ស្ថាប័ន

ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការ និងជាអនុប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែង បានដឹកនាំកិច្ចប្រជុំពិភាក្សាលើការរៀបចំដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសារធារណការនិងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់ផែនការក្របខណ្ឌឆ្នាំ២០២៣ នារសៀលថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ នៅទីស្តីការក្រសួងមុខងារសាធារណៈ។

កិច្ចប្រជុំពិភាក្សាពិនិត្យឯកភាពលើការងារសំខាន់ៗ ដែលនឹងត្រូវគិតគូរក្នុងដំណើរការរៀបចំការប្រឡងនាពេលខាងមុខមានដូចជា៖ ១)ការពិនិត្យសម្រេចបញ្ជីឈ្មោះបេក្ខជនប្រឡងប្រជែង ២)កំណត់ទីតាំងមណ្ឌលប្រឡងនិងកំណែវិញ្ញាសា ៣)ដំណើរការរៀបចំវិញ្ញាសាប្រឡងនិងសម្ភារៈគាំទ្រដំណើរការប្រឡង និង ៤)ការរៀបចំគណៈកម្មការនិងអនុគណៈកម្មការនានា។

សូមរម្លឹកផងដែរថា ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌ ក្រសួង-ស្ថាប័នទាំង៣ នឹងប្រព្រឹត្តទៅនៅតាមការបរិច្ឆេទដូចខាងក្រោម៖

- ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៤ ប្រឡងប្រជែង អង្គភាពប្រឆាំងអំពើពុករលួយ
- ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤ ប្រឡងប្រជែង ក្រសួងសាធារណការ និងដឹកជញ្ជូន
- ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤ ប្រឡងប្រជែង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងមុខងារសាធារណៈ រៀបចំកិច្ចប្រជុំអន្តរក្រសួង ពិនិត្យនិងពិភាក្សាលើការរៀបចំដំឡើងប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការក្នុងឆ្នាំ២០២៤

នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើការរៀបចំដំឡើងប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការក្នុងឆ្នាំ២០២៤ នៅសាលាភូមិន្ទរដ្ឋបាល ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នទាំងអស់ និងថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ សរុបចំនួនប្រមាណជិត ២០០នាក់។

មុនចាប់ផ្តើមកិច្ចប្រជុំ អង្គប្រជុំបានធ្វើកិច្ចស្មឹងស្មាតដើម្បីចូលរួមរំលែកទុក្ខចំពោះការយាងចូលព្រះទីវង្គតរបស់ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត នន្ទ ខេង** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហ៊ុន ម៉ានី បានមានមតិស្វាគមន៍ បើកអង្គប្រជុំ និងអនុញ្ញាតឱ្យ **លោក គឿន ប៊ុនធឿន** ប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងមុខងារសាធារណៈ ធ្វើបទបង្ហាញលើការរៀបចំសេចក្តីព្រាងអនុក្រឹត្យចំនួន៥ ពាក់ព័ន្ធនឹងការដំឡើងប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការក្នុងឆ្នាំ២០២៤ ព្រមទាំងបានដាក់អង្គប្រជុំជូនសមាជិក សមាជិកា អន្តរក្រសួង ដើម្បីពិនិត្យពិភាក្សាទៅលើអនុក្រឹត្យទាំង៥ រួមមាន៖

១)អនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារយោធិននៃកងយោធពលខេមរភូមិន្ទ ២)អនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីនគរបាលជាតិកម្ពុជា ៣)អនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ៤)អនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៥)អនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល។

ដោយឃើញមានការចូលរួមនូវមតិកែសម្រួល និងស្នើសុំបញ្ចូលតាមតម្រូវការ ព្រមទាំងការលើកឡើងនូវបញ្ហាផ្សេងៗរបស់បណ្ដាក្រសួង ស្ថាប័ន យ៉ាងផុលផុសដើម្បីឱ្យឧបសម្ព័ន្ធមានភាពច្បាស់លាស់រួចមក **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានកោតសរសើរដល់សមាជិក សមាជិកា ដែលបានចូលរួម ដែលការចូលរួមទាំងអស់នេះហើយ គឺជាស្មារតីនៃការគិតគូរទៅដល់ការអភិវឌ្ឍ និងការពារផលប្រយោជន៍របស់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់របស់យើង។

យោងតាមស្មារតីនៃកិច្ចប្រជុំ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានស្នើឱ្យក្រសួង ស្ថាប័ន ផ្ដល់ព័ត៌មានជាធាតុចូលដល់ក្រុមការងារបច្ចេកទេសបន្ថែមក្នុងរយៈពេលមួយសប្ដាហ៍ទៀត ដើម្បីកែសម្រួលឱ្យកាន់តែប្រសើរមុនដាក់ជូនថ្នាក់ដឹកនាំពិនិត្យបន្ត។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ហ៊ុន ម៉ានី** បានបន្ថែមថា កិច្ចប្រជុំក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល នាពេលនេះ គឺជាការអនុវត្តស្របតាមជវភាពនៃតួអង្គតែមួយ ដោយប្រកាន់យកនូវស្មារតីតែមួយ ក្នុងគោលដៅតែមួយ ហើយក្នុងនោះក្រសួងមុខងារសាធារណៈ មានបេសកកម្មមួយក្នុងចំណោមជាច្រើន នៃអាណត្តិទី៧ គឺសម្រេចឱ្យបាននូវចក្ខុវិស័យរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

ការពិភាក្សា អំពីផែនការសកម្មភាព របស់ក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ

នារសៀលថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវ ឈី ទិដ្ឋ៉ា** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ បានដឹកនាំកិច្ចប្រជុំក្រុមការងារដើម្បីពិនិត្យពិភាក្សាលើការងារមួយចំនួនរួមមាន៖ ១)ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ២)ផែនការសកម្មភាពនិងថវិកានៃគម្រោងទាំង២ ៣)ផែនការសកម្មភាពដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាសម្រាប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៤)ពិនិត្យវឌ្ឍនភាពការងាររបស់ក្រុមនីមួយៗ និង ៥)ផ្សេងៗ។ កិច្ចប្រជុំប្រព្រឹត្តទៅនៅសាលាភូមិន្ទរដ្ឋបាល ដោយមានអ្នកចូលរួម ចំនួនសរុប ១៥នាក់។

ក្រោយពីអង្គប្រជុំបានពិភាក្សាយ៉ាងល្អិតល្អន់រួចមក លោកជំទាវប្រធានបានថ្លែងការកោតសរសើរនិងវាយតម្លៃខ្ពស់ដល់ក្រុមការងារដែលបានសហការចូលរួមផ្តល់មតិយោបល់ ព្រមទាំងបានណែនាំដល់ក្រុមការងារយកទៅស្រាវជ្រាវបន្ត និងរៀបចំឱ្យបានទាន់ពេលវេលា។

ការពិនិត្យនិងពិភាក្សាលើផែនការសកម្មភាពឆ្នាំ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ សម្រាប់ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ

នៅរសៀលថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានអនុគណៈកម្មាធិការដឹកនាំប្រតិបត្តិនៃលេខាធិការដ្ឋាន គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ(គ.វ.រ.) បានដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើផែនការសកម្មភាពឆ្នាំ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ សម្រាប់ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ អនុប្រធាន និងសមាជិកនៃអនុគណៈកម្មាធិការប្រតិបត្តិ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ(គ.វ.អ.) អនុគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល(គ.វ.ស.) ព្រមទាំងឯកឧត្តមជំនួយការសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី និងមន្ត្រីជំនាញ សរុបប្រមាណ ៧៥នាក់ ។

កិច្ចប្រជុំបានប្រព្រឹត្តទៅដោយមានការជជែក និងពិភាក្សានិងពិគ្រោះយោបល់ ព្រមទាំងប្រមូលធាតុចូល ដើម្បីជាមូលដ្ឋានក្នុងការកែសម្រួលសេចក្តីព្រាងផែនការសកម្មភាព ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈសម្រាប់ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងសម្រាប់វិស័យសុខាភិបាល និងវិស័យអប់រំ។

ជាកិច្ចបញ្ចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** បានណែនាំដល់ក្រុមការងារកែសម្រួលផែនការសកម្មភាពស្របតាមស្មារតីអង្គប្រជុំយ៉ាងយូរ១សប្តាហ៍ក្រោយបញ្ចប់កិច្ចប្រជុំនាថ្ងៃនេះ ដើម្បីជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ប្រកបដោយប្រសិទ្ធភាព។

ផ្នែកទី២៖ សន្និសីទសារព័ត៌មាន

សន្និសីទអន្តរជាតិ ស្តីពីអនាគតវិស័យមុខងារសាធារណៈ

(តូក្យូ-ជប៉ុន)៖ **ឯកឧត្តម ឈុន សុជាតិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តំណាងក្រសួងមុខងារសាធារណៈ បានចូលរួមសន្និសីទអន្តរជាតិ ស្តីពី **«អនាគតវិស័យមុខងារសាធារណៈ»** ក្រោមអធិបតីភាព **លោកជំទាវ Kawamoto** រដ្ឋមន្ត្រីមុខងារសាធារណៈជប៉ុន និង **ឯកឧត្តម កៅ គឹមហួន** អគ្គលេខាធិការអាស៊ាន និងមានការចូលរួមដោយគណៈប្រតិភូជាអគ្គនាយក នៃមុខងារសាធារណៈអាស៊ានបូក៣។

សន្និសីទនេះរៀបចំឡើងដោយ អាជ្ញាធរបុគ្គលិកជាតិនៃប្រទេសជប៉ុន នាទីក្រុង តូក្យូ ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ត្រូវបានបិទបញ្ចប់ជាមួយការប្តេជ្ញាចិត្តបន្តកិច្ចសហប្រតិបត្តិការ និងការគាំទ្រគ្នាក្នុងក្របខណ្ឌអាស៊ានបូក៣ ដើម្បីជំរុញការកែទម្រង់វិស័យមុខងារសាធារណៈ ឱ្យកាន់តែប្រសើរឡើង។

ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ជាលើកដំបូង សម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៧ ដែលដឹកនាំអនុវត្តដោយក្រសួងមុខងារសាធារណៈ

(សន្និសីទសារព័ត៌មាន ស្តីពី «ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំឆ្នាំ២០២៣»)

ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើសន្និសីទ សារព័ត៌មានរួមគ្នាស្តីពី«**ការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣**»។

ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានថ្លែងក្នុងសន្និសីទរួមគ្នានេះដែរថាការប្រឡងចូលធ្វើជាមន្ត្រីកសិកម្មឃុំចំនួន២៥០នាក់ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ ធ្វើឡើងដោយស្មើភាព តម្លាភាព និងមិនឱ្យមានបែកវិញ្ញាសារប្រឡងនោះទេពោលគឺអ្នកចេះត្រូវប្រឡងជាប់ដោយសមត្ថភាព។

ឯកឧត្តមរដ្ឋមន្ត្រី ឌិត ទីណា បានថ្លែងបន្តថាមន្ត្រីកសិកម្មឃុំដែលប្រឡងជាប់ត្រូវតែជាអ្នកមានសមត្ថភាព មានឆន្ទៈបំពេញការងារ មានភាពឆ្លាតវៃក្នុងការជួយរកដំណោះស្រាយជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែលជួបបញ្ហាប្រឈមនានាលើវិស័យកសិកម្ម។

ផ្ទុយទៅវិញបើមន្ត្រីដែលប្រឡងជាប់ហើយមិនបានមកបំពេញការងាររបស់ខ្លួនឱ្យបានល្អទេនោះនឹងប្រឈមការលុបឈ្មោះចេញពីក្របខណ្ឌនិងប្រគល់ជូនបេក្ខជនបម្រុងធ្វើការងារជំនួសវិញ។ក្រោយពីប្រឡងជាប់មន្ត្រីទាំងនោះនឹងត្រូវឆ្លងកាត់ការធ្វើកម្មសិក្សារយៈពេលមួយឆ្នាំដើម្បីបំរើការងារនៅតាមឃុំនានាដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកំណត់។ **ក្រសួងមុខងារសាធារណៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**បានសហការគ្នាជ្រើសរើសមន្ត្រីកសិកម្មឃុំចំនួន២៥០នាក់សម្រាប់ឆ្នាំ២០២៣។បន្ទាប់មកនៅឆ្នាំ២០២៤ខាងមុខនេះក្រសួងគ្រោងនឹងបន្តជ្រើសរើសមន្ត្រីកសិកម្មឃុំចំនួន៨០០នាក់ទៀតខណៈនៅឆ្នាំ២០២៥នឹងបន្តជ្រើសរើសបង្គ្រប់ចំនួន៥៥០នាក់បន្ថែមទៀតដើម្បីឱ្យបានគ្រប់ចំនួន១៦០០នាក់ស្របតាមកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល។ចាប់តាំងពីដំណាក់កាលផ្សព្វផ្សាយទាំងការដាក់ពាក្យទាំងការរៀបចំនីតិវិធីនានាសម្រាប់ដំណើរការជ្រើសរើសការប្រឡង និងកំណែប្រឡងសុទ្ធតែត្រូវបានឆ្លងកាត់ការពិភាក្សានិងការគិតគូរពិចារណាយ៉ាងហ្មត់ចត់បំផុតដោយគណៈកម្មការជំនាញអន្តរក្រសួងធ្វើយ៉ាងណាដល់ការរៀបចំប្រព័ន្ធការជ្រើសរើសមួយដែលផ្តល់**ឱកាសឱ្យស្មើៗគ្នា មានតម្លាភាព មានយុត្តិធម៌ និងផ្អែកលើសមត្ថភាព**ពិតប្រាកដដូចអ្វីដែល **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានលើកឡើងថា«**ការជ្រើសរើសមន្ត្រីត្រូវឈរលើគោលការណ៍**«**ជាប់ដោយមោទនៈ ធ្លាក់ដោយអស់ចិត្ត**»។

សន្និសីទសារព័ត៌មានស្តីពី«ការរៀបចំការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា»

នារសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ ក្រសួងមុខងារសាធារណៈ និងក្រសួងអប់រំ យុវជន និងកីឡា បានធ្វើសន្និសីទសារព័ត៌មានរួមគ្នា ស្តីពី«ការរៀបចំការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា» ក្រោមគណៈធិបតីភាព **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការប្រឡងប្រជែង និង **ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន** តំណាងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងមានការអញ្ជើញចូលរួមពី តំណាងក្រសួងអប់រំ យុវជន និងកីឡា តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងអង្គភាពប្រឆាំងអំពើពុករលួយ (ACU) និងតំណាងសាលាភូមិន្ទរដ្ឋបាល ព្រមទាំងមានការចូលរួមពីអ្នកសារព័ត៌មានចំនួន ២១ស្ថាប័ន-អង្គភាព។

ផ្នែកទី៣៖ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល

សិក្ខាសាលាស្តីពី៖«ការកសាងសមត្ថភាពលើភាពជាអ្នកដឹកនាំប្រកបដោយបរិវត្តកម្ម សម្រាប់មន្ត្រីជាន់ខ្ពស់នៃប្រទេសជាសមាជិកអាស៊ាននិងប្រទេសទីម័រខាងកើត»

ឯកឧត្តម ហ៊ុន ម៉ានី អញ្ជើញជាអធិបតីបើកសិក្ខាសាលាស្តីពី៖ «ការកសាងសមត្ថភាព លើភាពជាអ្នកដឹកនាំប្រកបដោយបរិវត្តកម្ម សម្រាប់មន្ត្រីជាន់ខ្ពស់នៃប្រទេសជាសមាជិកអាស៊ាន និងប្រទេសទីម័រខាងកើត»

សៀមរាប៖ នាព្រឹកថ្ងៃចន្ទ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម ហ៊ុន ម៉ានី** **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** បានអញ្ជើញអធិបតីក្នុងពិធីបើកសិក្ខាសាលាស្តីពី **«ការកសាងសមត្ថភាពលើភាពជាអ្នកដឹកនាំប្រកបដោយបរិវត្តកម្មសម្រាប់មន្ត្រីជាន់ខ្ពស់នៃប្រទេសជាសមាជិកអាស៊ាន និងប្រទេសទីម័រខាងកើត»** នៅសណ្ឋាគារបុរីអង្គរនៅខេត្តសៀមរាប។ ក្នុងពិធីបើកសិក្ខាសាលានេះដែរមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈកម្ពុជា និងសិក្ខាកាមមកពីលេខាធិការដ្ឋានអាស៊ាន ប្រតិភូពីប្រទេសជាសមាជិកអាស៊ាន និងអាស៊ានបូករួមទាំងមន្ត្រីរាជការមកពីបណ្តាក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិប្រមាណ១៤០នាក់។

ជាកិច្ចស្វាគមន៍អង្គពិធី **ឯកឧត្តម ឈុន សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ បានធ្វើរបាយការណ៍សង្ខេបអំពីការរៀបចំសិក្ខាសាលាដោយបានបញ្ជាក់ថានៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការលើវិស័យមុខងារសាធារណៈអាស៊ានបូកបី ក្រសួងមុខងារសារធារណៈកម្ពុជាបានផ្តួចផ្តើមគម្រោងស្តីពី (Transformative Leadership) នៅក្នុងផែនការសកម្មភាព ២០២១-២០២៥ ដោយមានការគាំទ្រពីមូលនិធិកិច្ចសហប្រតិបត្តិការអាស៊ានបូកបី (ASEAN+3 Cooperation Fund)។

ថ្លែងប្រសាសន៍ក្នុងពិធីបើកអង្គសិក្ខាសាសាស្តីពី **«ការកសាងសមត្ថភាពលើភាពជាអ្នកដឹកនាំប្រកបដោយបរិវត្តកម្មសម្រាប់មន្ត្រីជាន់ខ្ពស់នៃប្រទេសជាសមាជិកអាស៊ាន និងប្រទេសទីម័រខាងកើត»** **ឯកឧត្តម ហ៊ុន ម៉ានី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** បានលើកឡើងអំពីសារៈសំខាន់នៃវិស័យមុខងារសាធារណៈនៅកម្ពុជា និងបានគូសបញ្ជាក់ថារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់អាទិភាពលើវិស័យនេះដោយបានដាក់បញ្ចូលការកែទម្រង់រដ្ឋបាលសាធារណៈក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១អាណត្តិទី៧ ក្រោមការដឹកនាំផ្ទាល់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមរដ្ឋមន្ត្រី** បានបន្ថែមថាសិក្ខាសាលានាថ្ងៃនេះគឺជាវេទិកាដ៏សំខាន់មួយសម្រាប់ថ្នាក់ដឹកនាំទាំងអស់មកពីប្រទេសសមាជិកអាស៊ាន និងអាស៊ានបូក និងមន្ត្រីកម្ពុជាដើម្បីជួបចែករំលែកការអនុវត្តល្អៗពីគ្នាទៅវិញទៅមកព្រោះភាពជាអ្នកដឹកនាំជាតម្រូវការសំខាន់និងចាំបាច់សម្រាប់កំណែទម្រង់វិស័យមុខងារសាធារណៈ។

សិក្ខាសាលានេះបានប្រព្រឹត្តទៅរយៈពេល៣ថ្ងៃគឺចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយមានការធ្វើបទបង្ហាញរបស់វាគ្មិនមកពីសាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋកូរ៉េ ប្រទេសជប៉ុន ប្រទេសដែលជាសមាជិកអាស៊ាន និងប្រទេសទីម័រខាងកើតលើប្រធានបទធំៗចំនួន៣និងវេទិកាពិភាក្សា (Panel Discussion) លើប្រធានបទចំនួន៤។

ពិធីបិទវគ្គបណ្តុះបណ្តាលនៃភាពជាអ្នកដឹកនាំ និងនវានុវត្តន៍

*លោកជំទាវ **ឈី វិថ្មរ៉ា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានអញ្ជើញជាអធិបតី ក្នុងពិធីបិទវគ្គ និងចែកសញ្ញាបនបត្រនៃសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីភាពជាអ្នកដឹកនាំនិងនវានុវត្តន៍ ជំនាន់ទី៥*

រសៀលថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ សាលាភូមិន្ទរដ្ឋបាលបានរៀបចំពិធីបិទវគ្គនិងចែកសញ្ញាបត្រនៃសិក្ខាសាលាបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំនិងនវានុវត្តន៍។ កម្មវិធីនេះមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ដែលជាថ្នាក់ដឹកនាំសាលាភូមិន្ទរដ្ឋបាលតំណាងសហភាពអឺរ៉ុបប្រចាំនៅកម្ពុជាតំណាងធនាគារពិភពលោកប្រចាំនៅកម្ពុជា តំណាងស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា តំណាងក្រសួងកិច្ចការនារី សាស្ត្រាចារ្យ និងគ្រូបង្គោលព្រមទាំងសិក្ខាកាមជំនាន់ទី៥ទាំងអស់សរុបចំនួនប្រមាណ២៥០នាក់។

កម្មវិធីបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងធនាគារពិភពលោកសហភាពអឺរ៉ុប និងស្ថានទូតអូស្ត្រាលី ជាមួយសាលាភូមិន្ទរដ្ឋបាលនៃក្រសួងមុខងារសាធារណៈដើម្បីគាំទ្រនិងអភិវឌ្ឍសមត្ថភាពមន្ត្រីជាន់ខ្ពស់ដែលជាអ្នកផ្តួចផ្តើមគន្លឹះនៅក្នុងវិស័យកែទម្រង់សំខាន់ៗនានាក្នុងក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល។

វគ្គបណ្តុះបណ្តាលនេះមានសារៈសំខាន់ណាស់សម្រាប់ថ្នាក់ដឹកនាំក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើរទាន់និន្នាការតំបន់ និងសកលលោកដែលមានការវិវត្តឥតឈប់ឈរនិងពិបាកព្យាករណ៍ទុកមុនដែលទាមទារឱ្យថ្នាក់ដឹកនាំត្រូវមានចំណេះដឹង និងចំណេះធ្វើជាប់ជាប្រចាំដើម្បីទទួលពុទ្ធិថ្មីៗ បទពិសោធន៍ល្អៗដើម្បីដឹកនាំអង្គភាព និងក្រសួង ស្ថាប័នឱ្យកាន់តែមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អស្របតាមការវិវត្តសភាពការណ៍ថ្មីៗ។ លោកជំទាវបាននាំប្រសាសន៍ផ្តាំផ្ញើរបស់ឯកឧត្តមរដ្ឋមន្ត្រីដល់សិក្ខាកាមទាំងអស់គួរចងចាំថា **"អ្នកដឹកនាំជាអ្នកកំណត់ទម្រង់នៃយុទ្ធសាស្ត្រក្នុងការឆ្លើយតបវិបត្តិដែលកើតឡើងនានា និងជាអ្នកបង្កើតបរិយាកាសនៅក្នុងអង្គភាពដែលអាចមានការគាំទ្រ ឬមិនគាំទ្រដល់នវានុវត្តន៍ពីថ្នាក់ក្រោម"**។

ចុងបញ្ចប់លោកជំទាវបានប្រកាសបិទវគ្គបណ្តុះបណ្តាលស្តីពី **"ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍" ជំនាន់ទី៥** ចាប់ពីពេលនេះតទៅ។ គួររម្លឹកបន្ថែមថាក្រសួងមុខងារសាធារណៈ សាលាភូមិន្ទរដ្ឋបាល និងធនាគារពិភពលោកបានរៀបចំការបណ្តុះបណ្តាលស្តីពី **"ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍"** ចំនួន ០៤វគ្គ រួចហើយ។ វគ្គជំនាន់ទី៥នេះបានចាប់ផ្តើមតាំងពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣កន្លងមករហូតដល់ខែធ្នូនេះដោយមានសិក្ខាកាមជាមន្ត្រីជាន់ខ្ពស់ចាប់ពីប្រធាននាយកដ្ឋានរហូតដល់រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងអភិបាលក្រុង ស្រុក ខណ្ឌរហូតដល់អភិបាលរាជធានីខេត្តសរុបចំនួន ១៩៧រូប ក្នុងនោះសិក្ខាកាមដែលបានបញ្ចប់វគ្គដោយជោគជ័យមានចំនួន ១៩៤រូប ស្មើនឹង ៩៨ %។

សិក្ខាសាលាចែករំលែកបទពិសោធនៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ របស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឆ្នាំ២០២៣

ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ បានលើកឡើងថា ការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ជាផ្នែកមួយនៃការបង្ហាញពីឧត្តមភាពនៃមន្ត្រីរាជការស៊ីវិលគ្រប់ជាន់ថ្នាក់ នៃការខិតខំប្រឹងប្រែងរបស់មន្ត្រីនីមួយៗ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងដូចនេះ នៅក្នុងពិធីបិទសិក្ខាសាលាចែករំលែកបទពិសោធនៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ របស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ឆ្នាំ២០២៣ នៅសាលមហោស្រពនៃមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ នារសៀលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤។

ជុំវិញការលើកឡើងនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសកម្មភាពនានានៃការអនុវត្តការងាររបស់មន្ត្រីរាជការស៊ីវិលគ្រប់ជាន់ថ្នាក់ទាំងអស់ ក្នុងគោលដៅបម្រើជាតិ និងប្រជាជន និងដើម្បីបង្ហាញពីឧត្តមភាពរបស់មន្ត្រីរាជការផង ព្រមទាំងអាចបង្កើននូវភាពជាគំរូ ដល់មន្ត្រីដទៃផ្សេងទៀតផងដែរ។

សូមបញ្ជាក់ថា ពិធីប្រកាសជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលឆ្នាំ២០២៣ នឹងប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។



ផ្នែកទី៤៖ លិខិតបទដ្ឋានគតិយុត្ត

ព្រះរាជក្រឹត្យ នស/រកត/០៩២៣/២១៤៣ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា



គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះ (គ.ជ.វ.) មានភារកិច្ចដូចតទៅ៖

- កំណត់និងដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ
- ដាក់ចេញនូវវិធានការចាំបាច់ ដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- កំណត់សូចនាករសមិទ្ធកម្មសម្រាប់ការអនុវត្តវិធានការគន្លឹះ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការគន្លឹះ
- តម្រង់ទិសនិងដោះស្រាយបញ្ហាពាក់ព័ន្ធ ដើម្បីធានាស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពនៃការអនុវត្ត វិធានការគន្លឹះ
- សហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍវិស័យឯកជន និងភាគីពាក់ព័ន្ធ លើការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីជំរុញនិងគាំទ្រការអនុវត្តវិធានការគន្លឹះ
- ធានាសង្គតិភាពនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈជាមួយការងារកែទម្រង់ក្នុងវិស័យ ផ្សេងៗរបស់រាជរដ្ឋាភិបាល ។

ព្រះរាជក្រឹត្យ នស/រកត/០៩២៣/២១៤១ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាល



គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ(គ.ជ.អ.) មានភារកិច្ចដូចតទៅ៖

- កំណត់និងដាក់ចេញវិធានការគន្លឹះ ក្នុងការពង្រឹងអភិបាលកិច្ចសាលា ការពង្រឹងចំណេះដឹង វិន័យ សីលធម៌និងឥរិយាបថរបស់សិស្ស ការលើកកម្ពស់សុខភាពរបស់សិស្ស និងការលើកទឹកចិត្តឱ្យមានការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ដាក់ចេញវិធានការចាំបាច់ដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- កំណត់សមិទ្ធកម្មនិងសូចនាករនៃការអនុវត្តវិធានការគន្លឹះ
- ដឹកនាំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការគន្លឹះ
- តម្រង់ទិសនិងដោះស្រាយបញ្ហាពាក់ព័ន្ធ ដើម្បីធានាស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- សម្របសម្រួលក្នុងកម្រិតគោលនយោបាយនិងយុទ្ធសាស្ត្រលើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងភាគីពាក់ព័ន្ធ ក្នុងការលើកកម្ពស់វិស័យអប់រំជាមួយការងារកែទម្រង់ក្នុងវិស័យផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

ព្រះរាជក្រឹត្យ នស/រកត/០៩២៣/២១៤២ ស្តីពីការរៀបចំការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាលរបស់រាជរដ្ឋាភិបាល



គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល (**គ.វ.ស.**) មានភារកិច្ចដូចតទៅ៖

- កំណត់និងដាក់ចេញនូវវិធានការគន្លឹះក្នុងការពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមដោយអង្គភាពសុខាភិបាលនៅមូលដ្ឋាន ជាពិសេស មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- ដាក់ចេញនូវវិធានការចាំបាច់ ដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- កំណត់សមិទ្ធកម្មនិងសូចនាករនៃការអនុវត្តវិធានការគន្លឹះ
- តម្រង់ទិសនិងដោះស្រាយបញ្ហាពាក់ព័ន្ធ ដើម្បីធានាស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពនៃការអនុវត្ត វិធានការគន្លឹះ
- សម្របសម្រួលក្នុងកម្រិតគោលនយោបាយនិងយុទ្ធសាស្ត្រនូវកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងភាគីពាក់ព័ន្ធ ក្នុងការពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន
- ធានាសង្គតិភាពនៃការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាលជាមួយការងារកែទម្រង់ក្នុង វិស័យផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

ព្រះរាជក្រឹត្យ នស/រកត/១០២៣/២៣១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ



គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.ក.ស.**) មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គាំទ្រ និងសម្របសម្រួលការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំនិងអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព
- ពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្ត គាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព
- សិក្សានិងរៀបចំក្របខណ្ឌគតិយុត្ត ដើម្បីលើកកម្ពស់គុណភាពនៃសេវាសាធារណៈ និងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ

- រៀបចំនិងដាក់ឱ្យអនុវត្តឯកសារក្របខណ្ឌសមត្ថភាពជាអ្នកដឹកនាំ និងវាយតម្លៃនិងទទួលស្គាល់ភាពជាអ្នកដឹកនាំគំរូក្នុងរដ្ឋបាលសាធារណៈ
- សិក្សាប្រព័ន្ធបៀវត្សរបស់រាជរដ្ឋាភិបាលជាលក្ខណៈកញ្ចប់ ដោយគ្របដណ្តប់ទាំងមន្ត្រីរាជការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ យោធិន មន្ត្រីនគរបាលជាតិ មន្ត្រីផ្សេងទៀត និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ព្រមទាំងលើកសំណើអំពីការកែទម្រង់ប្រព័ន្ធបៀវត្សជាលក្ខណៈកញ្ចប់
- សិក្សានិងរៀបចំការធ្វើវិចារណកម្មមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន
- គាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលនិងផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ពិនិត្យនិងសម្រេចលើសូចនាករសមិទ្ធកម្មគន្លឹះ និងដឹកនាំការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់រដ្ឋបាលសាធារណៈជូនរាជរដ្ឋាភិបាលនិងជំរុញការផ្សព្វផ្សាយសមិទ្ធផលនៃការងារកែទម្រង់រដ្ឋបាលសាធារណៈ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ដើម្បីជំរុញការងារកែទម្រង់រដ្ឋបាលសាធារណៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

អនុក្រឹត្យលេខ ៣២៥ អនក្រ.បក ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ



អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**អ.គ.ក.ស.**) មានតួនាទីជាសេនាធិការជូន **គ.ក.ស.** និងមានភារកិច្ចដូចតទៅ៖

- គាំទ្រដល់ការអនុវត្តមុខងាររបស់អនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍ អនុគណៈកម្មាធិការឧត្តមភាពសេវាសាធារណៈ អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស និងអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរបស់ **គ.ក.ស.**
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំគម្រោងសម្រាប់អនុវត្តការអប់រំ បណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន **គ.ក.ស.**
- សហការនិងសម្របសម្រួលជាមួយអង្គភាពនានាក្រោមឱវាទក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍គ្រប់អង្គភាព និងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈតាមការចង្អុលបង្ហាញរបស់ **គ.ក.ស.**។

អនុក្រឹត្យ ស្តីពីការដំឡើងរបបឧបត្ថម្ភប្រចាំខែសម្រាប់អ្នកនៅក្នុងបន្ទុករបស់សពមន្ត្រីរាជការស៊ីវិល សពអតីតមន្ត្រីរាជការស៊ីវិល និងសពអតីតយុទ្ធជន



អនុក្រឹត្យលេខ៣៧៤ អនក្រ.បក ស្តីពីការដំឡើងរបបឧបត្ថម្ភប្រចាំខែសម្រាប់អ្នកនៅក្នុងបន្ទុករបស់សពមន្ត្រីរាជការស៊ីវិល សពអតីតមន្ត្រីរាជការស៊ីវិល និងសពអតីតយុទ្ធជន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ មានគោលបំណងដំឡើងរបបឧបត្ថម្ភប្រចាំខែសម្រាប់អ្នកនៅក្នុងបន្ទុករបស់សព មន្ត្រីរាជការស៊ីវិល សពអតីតមន្ត្រីរាជការស៊ីវិល និងសពអតីតយុទ្ធជន ដើម្បីជួយសម្រាលការលំបាកផ្នែក ជីវភាពរស់នៅរបស់ជនទាំងនេះ។

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះអ្នកនៅក្នុងបន្ទុករបស់សពមន្ត្រីរាជការស៊ីវិល សពអតីត មន្ត្រីរាជការស៊ីវិល និងសពអតីតយុទ្ធជន អនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

ការដំឡើងរបបឧបត្ថម្ភប្រចាំខែដូចបានកំណត់ដូចក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ។

សេចក្តីជូនដំណឹង លេខ ១២០៥ ស.ជ.ណ ស្តីពីលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល



រាជរដ្ឋាភិបាលបានសម្រេចៈ

១.បន្តអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈដែលបានអនុវត្តកន្លងមក ដែលមានកំណត់ ក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់ រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីសម្រេចឱ្យបានជាលទ្ធផលជាក់ស្តែងក្នុងផ្នែកគន្លឹះនៃរដ្ឋបាលសាធារណៈដោយផ្តោតលើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័នតាមរយៈវិធានការដាក់ស្តែង រួមមានៈ

១.១-ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព

១.២-ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព

១.៣-ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព

២. ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ប្រកាន់យករបៀបនៃការគិតគូរថ្មីប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ក្នុងការពិចារណាដោះស្រាយស្ថានភាពចំពោះមុខពាក់ព័ន្ធនឹងការគ្រប់គ្រងនិងប្រើប្រាស់ធនធានមនុស្សដោយត្រូវអនុវត្តការត្រួតពិនិត្យឡើងវិញ ការវិភាគមុខងារស្ថាប័ន និងការកំណត់តម្រូវការធនធានមនុស្សឱ្យបានច្បាស់លាស់។

៣-ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ធ្វើការពិនិត្យ កែសម្រួល និងតម្រង់ទិសថវិកាឱ្យចំគោលដៅ ដោយត្រូវពិនិត្យមើលប្រភពថវិកាជាតិ ថវិកាដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រប្រសិទ្ធភាពការងារ សមិទ្ធកម្ម និងការលើកទឹកចិត្តផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពខ្ពស់។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ធ្វើការពិនិត្យតាមដាន និងវាយតម្លៃ ជាប្រចាំក្នុងន័យកំណត់ឱ្យបានច្បាស់លាស់នូវបញ្ហាប្រឈម ដើម្បីងាយស្រួលក្នុងការសម្របសម្រួល និងការគាំទ្រដល់ក្រសួង ស្ថាប័ន ផ្អែកលើគោលការណ៍រដ្ឋាភិបាលឯកភាព រដ្ឋបាលឯកភាព និងសម្លេងឯកភាពតែមួយក្នុងការបំពេញការងារ។

៥-ប្រគល់ភារកិច្ចជូនក្រសួងមុខងារសាធារណៈក្នុងនាមជាលេខាធិការដ្ឋាននៃ គ.រ.រ. ត្រូវជំរុញការរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈដោយត្រូវបន្សុី និងប្រទាក់ក្រឡាគ្នានូវសកម្មភាពនៃការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារ ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន ព្រមទាំងការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មឱ្យបានរួចរាល់ត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ ដោយក្នុងនោះ៖

៥.១.ត្រូវរៀបចំការប្រឡងជ្រើសរើសមន្ត្រីរាជការដាច់ដោយឡែកពីគ្នា ផ្តល់ជម្រើសច្រើនដល់បេក្ខជន ព្រមទាំងត្រូវអនុវត្តស្របតាមគោលការណ៍ថ្មីរបស់រាជរដ្ឋាភិបាលក្នុងក្របខណ្ឌនៃការកែទម្រង់រដ្ឋបាលសាធារណៈ។

៥.២-ត្រូវអនុវត្តឱ្យបានចប់សព្វគ្រប់នូវការពិនិត្យឡើងវិញរចនាសម្ព័ន្ធ និងការវិភាគមុខងាររបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រឹមត្រីមាសទី៣ឆ្នាំ២០២៤។ ទន្ទឹមនេះក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់មិនត្រូវបានអនុញ្ញាតឱ្យធ្វើការជ្រើសរើសមន្ត្រីរាជការឡើយក្នុងករណីមិនបានអនុវត្តការពិនិត្យឡើងវិញរចនាសម្ព័ន្ធនិងការវិភាគមុខងារ។

៥.៣-ត្រូវរៀបចំប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មក្នុងកម្រិតម៉ាក្រូដែលផ្តល់ការគាំទ្រពីរាជរដ្ឋាភិបាលឱ្យបានរួចរាល់ត្រឹមត្រីមាសទី៣ ឆ្នាំ២០២៤។ ទន្ទឹមនេះយន្តការលើកទឹកចិត្តផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានស្រាប់ត្រូវរក្សាទុក និងអនុវត្តដដែល។

៦. ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់បង្កើតឱ្យមានក្រុមការងារទទួលបន្ទុកអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភាឱ្យមានប្រសិទ្ធភាពប្រកបដោយបរិយាប័ន្ន សង្គតិភាព និងយុត្តិធម៌។

៧- ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ជំរុញការផ្លាស់ប្តូរផ្នត់គំនិតនិងរបៀបបំពេញការងារតាមទម្លាប់ ដោយត្រូវរៀបចំ និងអនុវត្តតាមគោលការណ៍ណែនាំច្បាស់លាស់ផ្អែកលើការពិគ្រោះយោបល់ទូលំទូលាយ និងឈរលើគោលការណ៍រួមចិត្ត រួមគំនិត និងរួមសកម្មភាព

៧.១- ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤ ជាដំណាក់កាលពិនិត្យឡើងវិញ និងរៀបចំកិច្ចការឱ្យរៀបរយ

៧.២- ពីឆ្នាំ២០២៥ ដល់ ឆ្នាំ២០២៦ ជាដំណាក់កាលអនុវត្តឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរ

៧.៣- ពីឆ្នាំ២០២៧ ដល់ឆ្នាំ២០២៨ ជាដំណាក់កាលពិនិត្យ និងវាយតម្លៃដើម្បីពង្រឹងនិងពង្រីកការកែទម្រង់។

អនុក្រឹត្យ ស្តីពីការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា

អនុក្រឹត្យ លេខ ០៤អនក្រ.បក ស្តីពី ការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា ចុះថ្ងៃទី៤ ខែមករា ឆ្នាំ ២០២៤ ។





ដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យាពី ចំនួន ៧១០ ០០០ ៛ (ប្រាំពីរសែនមួយម៉ឺន) រៀល ទៅ ៧៧០ ០០០ ៛ (ប្រាំពីរសែនប្រាំពីរម៉ឺន) រៀល។

ការដំឡើងប្រាក់កម្រៃប្រចាំខែដូចកំណត់ខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ។

ការដំឡើងប្រាក់កម្រៃដូចមានកំណត់ខាងលើ ត្រូវអនុវត្តចំពោះមន្ត្រីជាប់កិច្ចសន្យា ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យ លេខ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។

អនុក្រឹត្យ ស្តីពីការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល

អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ត្រូវបានទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលប្រចាំឆ្នាំ២០២៣ តាមលំដាប់ចំណាត់ថ្នាក់ ដូចខាងក្រោម៖





អនុក្រឹត្យ ស្ដីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ



អនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ ២០២៤ ស្ដីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន របស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា មានគោលបំណង កែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ នៃព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹត្យនេះមានគោលដៅកំណត់ ការដំឡើងតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និងកាលបរិច្ឆេទ នៃការអនុវត្តតម្លៃឯកតានេះ។

កែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានពីចំនួន ២៥០០ (ពីរពាន់ប្រាំរយ) រៀល ទៅចំនួន ២៦៣០ (ពីរពាន់ប្រាំមួយរយសាមសិប) រៀល ក្នុងមួយសន្ទស្សន៍។ តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាននេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ។

អនុក្រឹត្យ ស្ដីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិ សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល



អនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិ សម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល មាន គោលបំណងធានាបាននូវការជ្រើសរើសមន្ត្រីរាជការស៊ីវិល ប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព។ និយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡង ប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

និយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែង ជ្រើសរើសមន្ត្រីរាជការស៊ីវិល មានវិសាលភាពអនុវត្ត ចំពោះ ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ក្រោមច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា ក្នុងសមត្ថកិច្ចជ្រើសរើសរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ។

ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ត្រូវ រៀបចំនិងគ្រប់គ្រងដោយគណៈកម្មការរៀបចំការ ប្រឡង ប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ដែលជាយន្តការស្ថាប័ន រួមរបស់រាជរដ្ឋាភិបាល ដូចមានកំណត់ ក្នុងនិយាមនីតិវិធី ប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល។

ប្រកាសអន្តរក្រសួង ស្តីពីការដាក់ឱ្យដំណើរការការវាយតម្លៃនិងការទទួលស្គាល់ អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២៤

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ សូមជូនប្រកាសអន្តរក្រសួង ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យដំណើរការការវាយតម្លៃនិងការទទួលស្គាល់ អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២៤។ កំណត់យកមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាព បង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ ជាអង្គភាពផ្តល់សេវាសាធារណៈសម្រាប់ការវាយតម្លៃនិងការទទួលស្គាល់ អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២៤។ ការវាយតម្លៃនិងការទទួលស្គាល់មន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣គំរូ ត្រូវអនុវត្តអនុលោមតាមអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល និងត្រូវអនុវត្តផ្អែកលើតារាងលក្ខណៈវិនិច្ឆ័យដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។



ប្រកាសអន្តរក្រសួង ស្តីពីការដាក់ឱ្យដំណើរការការវាយតម្លៃនិងការទទួលស្គាល់ អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ សម្រាប់ឆ្នាំ២០២៤

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ សូមជូនប្រកាសអន្តរក្រសួង ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យដំណើរការការវាយតម្លៃនិងការទទួលស្គាល់ អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ សម្រាប់ឆ្នាំ២០២៤ ។ បានកំណត់យកវិទ្យាល័យ និងសាលាមត្តេយ្យសិក្សា(មត្តេយ្យសិក្សាធនធាននិងមត្តេយ្យសិក្សាដាច់ដោយឡែក) ជាអង្គភាពផ្តល់សេវាសាធារណៈ សម្រាប់ការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុង វិស័យអប់រំសម្រាប់ឆ្នាំ២០២៤។

ការវាយតម្លៃនិងការទទួលស្គាល់វិទ្យាល័យ និងសាលាមត្តេយ្យសិក្សាគំរូ ត្រូវអនុវត្តអនុលោមតាមអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល និងត្រូវអនុវត្តផ្អែកលើតារាងលក្ខណៈវិនិច្ឆ័យដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។



ប្រសាសន៍ណែនាំ

" ការដាក់ចេញនូវគោលនយោបាយជាប្រការសំខាន់
តែត្រូវមានអ្នកប្រតិបត្តិដ៏ស្មោះត្រង់ និងមានសមត្ថភាពគ្រប់គ្រាន់
ដើម្បីអនុវត្តទើបគោលនយោបាយជោគជ័យ "
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

អភិក្រមទាំង៥
របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
សម្រាប់មន្ត្រីអនុវត្តការងារប្រចាំថ្ងៃ
"ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល ព្យាបាល វះកាត់"
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រសាសន៍ណែនាំ

ក្រៅពី "ការកែទម្រង់ការប្រឡងជ្រើសរើសមន្ត្រីរាជការ តាមរយៈ
ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ
តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព"
កិច្ចការដែលជាអាទិភាពគន្លឹះមួយផ្សេងទៀត របស់ក្រសួងមុខងារសាធារណៈ
គឺ "ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការងារ
ប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព"
នាយករដ្ឋមន្ត្រី
សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ចាប់តាំងពីដំណាក់កាលផ្សព្វផ្សាយទាំងការដាក់ពាក្យ
ទាំងការរៀបចំនីតិវិធីនានា សម្រាប់ដំណើរការជ្រើសរើសការប្រឡង
និងកំណែប្រឡងសុទ្ធតែត្រូវបានឆ្លងកាត់ការពិភាក្សា
និងការគិតគូរពិចារណាយ៉ាងហ្មត់ចត់បំផុត ដោយគណៈកម្មការជំនាញអន្តរក្រសួង
ធ្វើយ៉ាងណាដល់ការរៀបចំប្រព័ន្ធការជ្រើសរើសមួយ ដែលផ្តល់ឱកាសឱ្យស្មើៗគ្នា
មានតម្លាភាព មានយុត្តិធម៌ និងផ្អែកលើសមត្ថភាពពិតប្រាកដ
ដូចអ្វីដែល សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី បានលើកឡើងថា
ការជ្រើសរើសមន្ត្រីត្រូវឈរលើគោលការណ៍
"ជាប់ដោយមោទនៈ ធ្លាក់ដោយអស់ចិត្ត"
សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រសាសន៍ណែនាំ

មន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ ប្តេជ្ញា និងគោរពអនុវត្តក្នុងស្មារតីកំណែទម្រង់ឥតងាករេ ស្របតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងតាមទស្សនវិស័យរបស់រាជរដ្ឋាភិបាល។

ប្រសាសន៍ **ឯកឧត្តម ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ថ្លែងក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃសាលាភូមិន្ទរដ្ឋបាលនាព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០២៣។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការ កែទម្រង់រដ្ឋបាលសាធារណៈ

គណៈគ្រប់គ្រង៖

ឯកឧត្តម	ឈុន សុជាតិ	អគ្គលេខាធិការ
ឯកឧត្តម	សិក ហេងឡុង	អគ្គលេខាធិការរង
ឯកឧត្តម	សួន រស្មី	អគ្គលេខាធិការរង
ឯកឧត្តម	ជា ឡាលីន	អគ្គលេខាធិការរង
ឯកឧត្តម	គង់ សុវត្ថិភាព	អគ្គលេខាធិការរង
ឯកឧត្តម	សុខ វឌ្ឍនៈ	អគ្គលេខាធិការរង
ឯកឧត្តម	ប្រាក់ ប្រានីដ្ឋា	អគ្គលេខាធិការរង
លោកជំទាវ	តឹក កុស្សនា	អគ្គលេខាធិការរង
ឯកឧត្តម	សៀត វិចិត្រ	អគ្គលេខាធិការរង

ព្រឹត្តិបត្រព័ត៌មានកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ

រៀបរៀង និងចងក្រងដោយ ៖

នាយកដ្ឋានសម្របសម្រួលការងារកែទម្រង់អន្តរវិស័យ

លោក	សុខ សំណាង	ប្រធាននាយកដ្ឋាន
លោក	ម៉ិច សៀកឡេង	អនុប្រធាននាយកដ្ឋាន
លោកស្រី	យិន ស័យយ៉ាណា	អនុប្រធាននាយកដ្ឋាន
លោកស្រី	នាក់ តុលា	អនុប្រធាននាយកដ្ឋាន
លោកស្រី	ឈុន ពុទ្ធានី	អនុប្រធាននាយកដ្ឋាន
លោក	ងុធ ចំណាន	អនុប្រធាននាយកដ្ឋាន
លោកស្រី	នុត សម្ផស្ស	ប្រធានការិយាល័យ
លោកស្រី	ស៊ឹម សុគន្ធ	ប្រធានការិយាល័យ
លោកស្រី	ពៅ ធីតា	ប្រធានការិយាល័យ
លោកស្រី	ហាង្ស វិទូ	ប្រធានការិយាល័យ
កញ្ញា	ឌីណា ស៊ីថាមុនីរ័ត្ន	អនុប្រធានការិយាល័យ
កញ្ញា	ខ្លូង សុជាតា	អនុប្រធានការិយាល័យ
លោក	សុយន ម៉ិនហេង	មន្ត្រី
លោកស្រី	សេង គន្ធា	មន្ត្រីជាប់កិច្ចសន្យា
លោកស្រី	ណុប ចាន់ដាណា	មន្ត្រីជាប់កិច្ចសន្យា

ចូលរួមសហការផ្សេងៗ ៖

នាយកដ្ឋានកិច្ចការទូទៅ

នាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃ

អគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ទាញយកព្រឹត្តិបត្រព័ត៌មាន

អាស័យដ្ឋាន ៖#លេខ១៧ ផ្លូវ៤៦៦ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
គេហទំព័រ : http://www.mcs.gov.kh
Facebook Page : ក្រសួងមុខងារសាធារណៈ Ministry of Civil Service Cambodia